# ការសំភាសន៍របស់អ្នកមីង " ជុន រ៉េន "

ក ៖ អ្នកសំភាសន៍មានឈ្មោះ អ៊ុំកន្និកា ខ ៖ អ្នកដែលត្រូវគេសំភាសន៍ ជុន រ៉េន

កៈ ជំរាបសួរអ្នកមីងហើយជាដំបូងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកមីងដែលបានអនុញ្ញាតអោយក្មួយដើម្បីធ្វើការសំភាសន៍អ្នកមីងទាក់ទងទៅនិងជីវប្រវត្តិផ្ទាល់ខ្លួនរបសអ្នកមីងផងដែរហើយការសំភាសន៍មួយនេះគឺធ្វើឡើងដោយសាលាសកលវិទ្យាល័យ BYU (ប៊ីវ៉ាយយូ)ដោយសារតែសាលាសកលវិទ្យាល័យយើងនិងមានបំណងចង់ថែរក្សានូវជីវប្រវត្តិរបស់ប្រជាជនកម្ពុជាទុកសំរាប់កូនចៅជំនាន់ក្រោយដើម្បីគេអាចដឹងលឺនិងស្គាល់អំពីខ្សែជីវិតរបស់មនុស្សជំនាន់មុនផងដែរហើយបន្ទាប់ពីការបញ្ចប់នូវការសំភាសន៍មួយនិងក៏ពួកយើងសុំការអនុញ្ញាតពីអ្នកមីងដើម្បីដាក់សំលេងអ្នកមីងចូលទៅក្នុងគេហទំព័ររបស់សាលាយើងដែលមានឈ្មោះថា www.cambodia.noralhistories@by.edu ផងដែរហើយខ្ញុំជាអ្នកសំភាសន៍គឺឈ្មោះ អ៊ុំ កន្និកា ហើយធ្វើឡើងគឺនៅថ្ងៃទី 15 ខែមីនា ឆ្នាំ 2018 ហើយទីកន្លែងគឺនៅភូមិ ភ្នំក្រោមផងដែរហើយយើងនិងទៅជួបគាត់ទាំងអស់គ្នា! ជំរាបសួរអ្នកមីង!

ខៈ ចា៎(សើច)

កៈ តើអ្នកមីងមានឈ្មោះអ្វីដែរ?

ខៈ ខ្ញុំឈ្មោះ ជុន រ៉េន!

កៈ ជុន រ៉េន?

ខៈ ចា៎!

កៈ ចា៎ចុះអ្នកមីងដូចជាមានឈ្មោះហៅក្រៅទេ?

ខ៖ ហៅក្រៅឈ្មោះ រ៉េនៗ

ក៖ ចាំគេហៅក្រៅតែរ៉េនៗនេះឯងណោះអ្នកមីងណោះ?

ខ៖ ចាំ!

ក៖ ចុះកាលនៅពីក្មេងវិញមានរហំសនាមអ្វីផ្សេងទៀតទេ?

ខ៖ អត់ៗៗមានអីទេមានតែមួយ!

ក៖ អំចាំមានតែឈ្មោះមួយនេះឯង?

ខ៖ ចាំមានតែឈ្មោះរ៉េនមួយមុខនេះឯង!

ក៖ តើអ៊ុំគិតថាឈ្មោះ រ៉េន មួយនេះតើម្ដាយឪពុកអ៊ុំជាអ្នកដាក់អោយឬក៏យាយតាដែរ?

ខ៖ អត់មានយាយតាទេគាត់ស្លាប់ជំនាន់អាពតអស់ហើយលោកពុកក៏គាត់អត់ដែលឃើញដែលម្ដាយអ្នកដាក់!

ក៖ អំម្ដាយអ្នកដាក់អោយ?

ខ៖ ចាំ!

ក៖ អញ្ចឹងអ្នកមីងប្រើឈ្មោះនេះយូរហើយ?

ខ៖ អត់ដែលប្ដូរសោះ!

កៈ ចាំស្រលាញ់!

ខៈ ទោះដល់ទីណាក៏ប្រើឈ្មោះតែ រ៉េន ព្រោះនៅភ្នំក្រោមមានឈ្មោះរ៉េនតែពីរនាក់ទេម្នាក់ទៀតនោះងាប់ហើយចឹងឈ្មោះនេះសល់តែខ្ញុំមួយប៉ុនណោះឯងអត់មានទេ!

កៈ អ៎ចាំឈ្មោះរ៉េនមានតែមួយ!

ខៈ ចាំបើមានឈ្មោះរ៉េនៗប្រុស

កៈ ចាំចុះដូចជាអាយុរបស់អ្នកមីងវិញតើអ្នកមីងមានអាយុប៉ុន្មានហើយ?

ខៈ អាយុ ហែសិបបួនហើយសែសិបបួនឆ្នាំថ្មីយើងនិងឯងឆ្នាំរោងហ៊ីសែសិបបីអ្ហែអ៊ីអ៎និងហើយសែសិបបីទេសែសិបពីរសែសិបបីឆ្នាំរោង

កៈ អូយក្មួយអត់សូវចេះរាប់អានិងដែរតែអ៊ុំគិតថាខ្ទង់សែសិបបីហែសិបបួនណោះអ៊ុំណោះ?

ខៈ និងហើយ!

កៈ ចុះតើអ៊ុំស្រីមាននៅចាំអំពីឆ្នាំកំណើតថ្ងៃខែឆ្នាំកំណើតអ្នកមីងចាំទេ?

ខៈ អឺកឆ្នាំយើងដឹងតែឆ្នាំរោងហើយខែវិញគឺខែផល្គុនថ្ងៃព្រហស្បត្តិ៍!

កៈ ថ្ងៃព្រហស្បត្តិ៍អ៎ចាំអ្នកមីងចាំច្បាស់ណាស់ចុះដូចជាទីកន្លែងកំណើតវិញតើអ្នកមីងដឹងថាអ្នកមីងកើតនៅទីណាទេ?

ខៈ អ៎អង្កាលកើតនិងម្ដាយខ្ញុំប្រាប់ថា1975(មួយពាន់ប្រាំបួនរយចិតសិបប្រាំ)អង្កាលនោះមុនអាពតឬក៏រួចអាពត

កាលនោះ?

កៈ ឆ្នាំមួយពាន់ប្រាំបួនរយចិតសិបប្រាំចូលអាពតម៉ងអ្នកមីងពេលមួយពាន់ប្រាំបួនរយចិតសិបប្រាំបួនបានយើងរួចផុតមក!

ខៈ និងពេលនិងឯងចាំឆ្នាំមួយពាន់ប្រាំបួនរយចិតសិបប្រាំ(1975)មីងគិតថាមួយពាន់ប្រាំបួនរយចិតសិបបួន(1974)មួយពាន់ប្រាំបួនរយចិតសិបប្រាំ(1975)អីនិងដូចថាយើងចាប់ផ្តើមចិតសិបបួនអញ្ចឹងវាកំពុងពេញចឹងអ្វីណាស់ចិតសិបប្រាំទៅយើងរំដោះបានខ្លះៗអញ្ចឹងតែមីងនៅតូចៗពេកអត់ដឹងរឿងអីទេ

កៈ ចាំចុះអ្នកមីងអាចដឹងថាអ្នកមីងកើតនៅកន្លែងណាទេ?

ខៈ អត់ៗដឹងអត់ដឹងសោះតូចពេក

កៈ អ៎ចាំ

ខៈ ខ្ញុំថាតែងាប់បាត់ហើយតាសខ្ញុំឈឺឡើងម៉ែថាឡើងទុកចោលហើយនិងមិនបានយកទៅមើលទេងាប់ក៏ងាប់ទៅបើឈឺដល់កហើយយើងនៅកាលនោះមានថ្នាំឯណាលេបគ្មានអ្នកណាមើលអ្នកណាទេតំបន់និងលីម៉ែថានែកបើកន្លែងល្អមានអីគេអោយស៊ីផ្អែតតាសអោយស៊ីផ្អែតមើលតែកន្លែងមិនល្អសំលាប់យើងហើយអត់អោយយើងស៊ីផ្អែតទៀតវាយ៉ាប់អញ្ចុះឯងនេះលីតែពាក្យគាត់ថាតែមីងពេលនិងនៅតូចពេក!

កៈ ឆ្លៀតកើតសង្គ្រាមហើយអ្នកមីងកើតមកនៅក្នុងសម័យនុងហើយឆ្លៀតឈឺច្រើនទៀតណោះអ្នកមីង?

ខៈ ឈឺទៀតឈឺច្រើនណាស់ពេលនិងហើមដៃហើមជើង

កៈ ពេលនិងមានថ្នាំមកពីណា?

ខ៖ មានឯណាពេលនិង!

ក៖ មនុស្សស្រសម៉យនោះអោយតែឈឺគឺភាគតិចណាស់ដែលរស់អ្ហោះ

ខ៖ មិនដែលមានអីហូបទេមានតែដើមចេកបបរនុងឯងគាត់និយាយអ្ហាសថាគាត់ពិបាកពេកទៅគាត់ទុកចោលក្របក្រណាត់សទុកចោលនិងគាត់ថាងាប់ក៏ងាប់ពេលគាត់ម៉ោវិញទៅក៏លីសំលេងដង្ហើមផ្អឹកៗម៉ោក៏លើកកូនទៅមើលទៅណាំចៃដន្យគាត់ថាអញ្ចេកថាកុំអីក៏អត់រស់ដែរគាត់និងកាលនោះគាត់ចេះឆ្មបចេះឆ្មបទៅដូចថាមិត្តអ្ហាសប្រពន្ធមិត្តអ្ហាសគេឈឺពោះកើតកូននិងគេហៅគាត់ទៅបង្កើតដល់កើតហើយប្រពន្ធគេសុខសប្បាយគេចែកបាយចែកទឹកចែកថ្នាំអោយគួបទៅណាស់ក៏បានមីងរស់កុំអីមីងងាប់បាត់ហើយៗមីងនិងពៅគេដែលប្ដីគេម្ដាយឪពុកបានស្ទើរទៅអាពតទៅណាំពៅគេលីតែគាត់និយាយទេណាស់មីងអត់ដឹងទេដល់ពេលមីងត្រឹសម៉ោទើបមីងដឹងសាច់រឿងមីង?នៅជំរុំងណោះទេមីងអត់ដឹងទេ!

ក៖ ចុះបងប្អូនបង្កើតរបស់អ្នកមីងមានចំនួនប៉ុន្មាននាក់ដែរ?

ខ៖ ប្រាំបីនាក់!

ក៖ អូដល់ទៅប្រាំបីនាក់

ខ៖ ប្រាំបីនាក់

ក៖ ស្រីប៉ុន្មានប្រុសប៉ុន្មានដែរ?

ខ៖ ស្រីបីស្រីបួនអ្ហ៎មិនមែនប្រាំបីនាក់ទេប្រាំពីរនាក់

ក៖ អំតែប្រាំពីរនាក់ទេ

ខ៖ ចាំស្រីបីប្រុសបួន

ក៖ ស្រីបីប្រុសបួន?

ខ៖ ចាំ!

ក៖ អូអក្មេងអ្នកមីងពៅគេ?

ខ៖ ចាំខ្ញុំពៅគេ

ក៖ ចុះតលូវសព្វថ្ងៃពួកគាត់រស់នៅទីណាដែរ?

ខ៖ ខ្លះគេទៅថៃទៅហើយខ្លះទៀតគេទៅគេបានប្រពន្ធអីទៅនៅឯអង្គរក្រោងណោះតែអ្នកខ្លះអីនៅនិងជុំវិញនេះឯងនៅនិងផ្ទះម្ដាយនៅក្រៅនៅតែម្ដាយទេ!

ក៖ អំចាំអក្មេងគាត់ប្រកបមុខរបរអីគេដែរអ្នកមីង?

ខ៖ ម្ដាយចាស់ហើយគាត់សន្សំសិល្ប៍ហើយគាត់ឡើងប៉ែតសិបឆ្នាំជាងហើយម្ដាយអ្នាសគាត់ចាស់ហើយគាត់មិនបានធ្វើអីទេខ្ញុំក៏អត់បានធ្វើអីដែរនៅតែផ្ទះទេណាហ៊ានព្រោះឪវាមិនោយទៅរកអីទេណាមួយយើងលើសឈាមផងហើយឧស្សាហ៍

ក៖ អំមានជំងឺជាប់ខ្លួនផង?

ខ៖ ចាំហើយឧស្សាហ៍រើជំងឺបេះដូងផងពេកបើយើងទៅធ្វើអីទៅវាដួលវាដំទៅ១ជាស្ទឹកអ្នាសខ្លាចអញ្ចេះឯងហើយវាមិនដែលបានប៉ុន្មានទេកូនស្រីយើងទៅរកបានមួយម៉ាក់មួយម៉ឺនពីរម៉ឺននោះឯងចុះបើឈឺមើលមិចជាមួយម៉ឺនពីរម៉ឺននិងអាព្យាបាលពួកនិងសុទ្ធតែតម្លៃរាប់ម៉ឺនដុល្លាហើយអានិងជំងឺអ្នកមានយើងក្រចេះមើលអីអូន

មានណាគេមើលអីកើតទេ

កៈ ចាំចុះដូចជាបងប្អូនអ្នកមីងគាត់ប្រកបមុខរបរអីដែរឮថ្ងៃ?

ខៈ អូខាងបងប្រុសខ្ញុំទីបួននោះគាត់ធ្វើស្រែទោងដើងអង្គរក្រៅចាំគាត់ធ្វើស្រែហើយបងស្រីក្រោយគេនោះគាត់ទម៉ាស្សាម៉ាសអីរត់តែអ៊ីទេមិនដែលបានទៅនិងគេទេប្ដីអត់អោយទៅទេ

កៈ តែផ្ទះរបស់ពួកគាត់នៅម្ដុំៗនេះដែរណោះអ្នកមីង?

ខៈ ចាំនៅម្ដុំនេះឯងខ្លះនៅជើងទំនប់ខាងណោះអាជើងទំនប់ថ្នល់ក្រហមទៅណោះអ្វីណាស់នោះឯង

កៈ ចាំតែសុទ្ធតែនៅក្រវែលៗម្ដុំភ្នំក្រោមនិងទាំងអស់?

ខៈ ចាំៗនៅជុំវិញនេះឯង!

កៈ អញ្ចឹងបើចង់មានបុណ្យទានអីស្រួលស្រណុកមិនបាច់ជិះរកគ្នាដើរលេងឆ្ងាយអ្នាស

ខៈ ចាំ

កៈ ចុះដូចជាតើអ្នកមីងអាចប្រាប់ឈ្មោះរបស់ពួកគាត់បានទេថាគាត់ឈ្មោះអីភេទអីអញ្ចឹងអ្វីណាស់ចាប់ពីបងច្បងម៉ោ?

ខៈ អ៎នែកឈ្មោះនែកបងច្បងនោះឈ្មោះនែកអឺកស្ទីសែមអ៎ឈ្មោះ ជុន សែម

កៈ ជុន សែម?

ខ៖ ចាំនែកទីពីរម៉ោនែកឈ្មោះ ជុន ជឿន ទីបីម៉ោឈ្មោះ ជុន ឡឿន ហើយទីបួនម៉ោអឺកឈ្មោះ ជុន រាន់ ចុះងាប់មួយមិនបាច់និយាយអ្ហែណោះ?

ក៖ ចាំ

ខ៖ នោះឯងងាប់មួយទៅបានដល់ជុន រ៉េននិងខ្ញុំនេះឯងប៊ិនខ្ញុំអត់យកឈ្មោះលោកពុកទេខ្ញុំយកឈ្មោះម្ដាយដាក់ព្រោះម្ដាយខ្ញុំនៅរស់ចាំប៉ុន្តែខ្ញុំតែងប្រាប់គេថាឈ្មោះ សាត អាបឈ្មោះ សាតរ៉េន ប៉ុន្តែថ្ងៃខ្លះខ្ញុំប្រាប់គេថាឈ្មោះ ជុន រ៉េនអញ្ចេះ។

ក៖ ចាំចុះឈ្មោះ ជុន រាន់?

ខ៖ ឈ្មោះ ជុន រាន់និងបន្ទាប់ដូចថាខ្ញុំពៅគេអញ្ចឹងបន្ទាប់ខ្ញុំវានោះឯង។

ក៖ អ៎ចាំតែគាត់ស្លាប់បាត់ហើយ?

ខ៖ អត់ទេស្លាប់នែកអឺកបងគេបំផុតអត់ស្គាល់ទេ

ក៖ គាត់ឈ្មោះអីគេទៅ?

ខ៖ ខ្ញុំអត់ស្គាល់ទេខ្ញុំអត់ស្គាល់ព្រោះម្ដាយអត់ដែលនិយាយផង

ក៖ អូអត់ដែលរំលឹកពីគាត់សោះ?

ខ៖ អត់! កាលណោះព្រោះវាកើតម៉ោបានប៉ុន្មានថ្ងៃងាប់ដូចថាវាៗនេះទឹកភ្លោះពីកំណើតម៉ោបណ្ដោយអឺណាស់កាលណោះបងនោះមុននែកមុនអាពតអ្ហោះគាត់កើតម៉ោមុនអាពតទៀតណោះបងនោះណាំមុនយូរតែមែនទែន

ចុះគាត់ឡើងចូលហាសិបហើយវាមិនមុនៗឆ្ងាយអ្នាស

កៈ ចាំអញ្ចឹងដូចជាតើអ្នកមីងដូចថាអ្នកមីងនៅចងចាំអំពីសាច់រឿងអនុស្សាវរីយ៍ចាស់ៗជាមួយនិងបងប្អូនអ្នកមីងថាធ្លាប់ធ្វើអ្វីខ្លះជាមួយគ្នាអញ្ចឹងអ្នាស?

ខៈ បងប្អូនខ្ញុំចប់បាត់ហើយ(សើច)មិនដែលសូវស្និតស្នាលនិងគ្នាទេហើយមានឈ្មោះតែបងប្អូនមែនតែមិនសូវស្និតស្នាលនិងគ្នាទេអត់គេរស់នៅតែគេខ្ញុំរស់នៅតែខ្ញុំទៅហើយយើងអត់អីអាចពឹងពាក់គ្នាអីអត់បានទេហើយមិនដែលបានពឹងពាក់គ្នាទេព្រោះគ្រួសារយើងអត់ដែរយើងមិនបានដូចថាខ្ញុំអត់អញ្ចឹងទៅរកគេអញ្ចឹងគេមានគេអោយតែគ្នាអត់ដែរពេលខ្ញុំមានអញ្ចឹងគេមករកខ្ញុំដូចថាគ្នាទាល់អីគេមករកខ្ញុំៗក៏ទាល់ដូចតែគ្នានិងដែរខ្ញុំមិនសូវមាននិងគេទេ។

កៈ ចាំចុះកាលនៅពីក្មេងអីថាមានធ្លាប់នៅជាមួយម៉ែឪទាំងអស់គ្នាអ្នាសដូចថាកាលណោះពួកគាត់មានសាមគ្គីគ្នារស់នៅជាមួយគ្នាយ៉ាងចុះសំរុងអីបែបណាអញ្ចឹងអ្នាស?

ខៈ អំមានអីធម្មតាតាស!

កៈ កាលនៅពីក្មេងនិងអ្នាស?

ខៈ ចាំៗ!

កៈ អំចាំចឹងកាលនៅក្រោមបន្ទុកឪពុកម្ដាយអត់អីទេ?

ខៈ ចាំអត់អីទេអូន!

កៈ ចាំដូចថាចេះស្រលាញ់គ្នាអីធម្មតាណោះអ្នកមីងណោះ?

ខ៖ ចាំធម្មតាស្រលាញ់គ្នា!

ក៖ ចុះជាធម្មតាចូលចិត្តធ្វើការងារអីជាមួយគ្នាដែរ?

ខ៖ កាលនៅជំរុំនោះដើរពេញតែវាលនិង(សើច)មានអីដើរ

ក៖ ជំរុំនិងកន្លែងណាដែលទៅ?

ខ៖ ជំរុំយើងនៅប្រទេសថៃនៅបរិវេណប្រទេសថៃមើសមានបាំងកក ស៊ីៗកេត អីអញ្ចឹងអីណាស់អង្កាលនោះយើងនៅជំរុំកាលខ្ញុំនៅជំរុំនោះអង្កាលនោះកាលរដ្ឋកម្ពុជានោះខ្មែរយើងមិនចែកប៉ាក់គ្នាអ្ហោះពេលនិងមានទាំងខ្មែរសំលាប់ខ្មែរទៀតណោះទៅគេចែកប៉ាក់គ្នាទៅខ្ញុំនៅខាងរ៉ាមរិទ្ធសម្តេចរ៉ាមរិទ្ធអ្ហាសពេលម៉ោនេសដល់ទៅកោសិបបី(1993)យើងដឹកឃើញនៃកយកប្រជាជនចូលខ្មែរម៉ោគេទទួលបានឯករាជហើយណាស់ទៅក៏យកម៉ោៗចូលឯករាជនិងឯងទៅមីងនៅខាងដល់សព្វថ្ងៃនិយាយទៅយើងនៅមានម្លប់ទីណាយើងចេះតែនៅតានិងទៅណាស់ យើងមិនបាច់រើរុកអីពីដើមមិញក៏យើងលុបលាងទៅយើងមិនបាច់និយាយវ៉ែងឆ្ងាយអីតែមីងនៅនិងមីងដឹងនោះមីងកាលនិងទូចមែនតែមីងដឹងថាម៉ែគាត់មានប្តីប៉ារ៉ាប្តីចុងអ្ហោះនៅតាតាមគាត់ទេបើនិយាយពីដើមមីងដើរតែចូលតែព្រៃនិងមីងដើរឃើញអាពតឃើញអីរស់ចុះមីងមានខ្លាចអីឃើញអាពតដាំបាយឃើញអាពតនៅក្នុងជំរុំវ៉ាទៀតណ៎ហើយដើររហូតមីងដើរតែព្រៃទេមីងស្គាលតែរស់ជាតិព្រៃនិងមិនដែលស្គាល់រសជាតិក្រុងនិងគេទេនៅនិងក៏អញ្ចឹងទើបតែប្រជាជនចូលមកយកដីទេកាលមុនដីមីងតើនាគចាប់ពីនេះម៉ោទៅដល់ក្រោមដីមីងទាំងអស់មីងនៅមីងនៅការពារព្រៃមីងបោចតែដៃទេមីងអត់មានអីទេហើយគ្មាននរណាម៉ោធ្វើអីទេដល់ស្រុកឯករាជគេថាដ?គេក៏មីងខ្ជិលដណ្តើមមានទំនាស់មីងក៏អោយគេទៅមីងខ្ជិលប្រកែកព្រោះមីងកាន់សិល្បធម៌គុណធម៌មីងអត់ប្រកាន់មីងអត់ប្រកែកតេសនិងឯង

ក៖ ចាំអញ្ចឹងចែកគ្នានៅទៅ?

ខ៖ ចាំចែកទៅមីងមិនបានថាអីទេស!

ក៖ ចាំចុះម្ដាយរបស់អ្នកមីងវិញមានឈ្មោះអ្វីដែរ?

ខ៖ អឺកគាត់ឈ្មោះ សាត អាត គាត់យកតាមឈ្មោះលោកពុកគាត់ឈ្មោះ សាត ទៅក៏ឈ្មោះគាត់ សាត អាត។

ក៖ អំចាំអក្មើងចុះដូចជាឪពុកវិញឪពុករបស់អ្នកមីង?

ខ៖ អត់ស្គាល់ផង! អត់ស្គាល់

ក៖ អូចាំគាត់ឆាប់ស្លាប់ពេកឬក៏យ៉ាងណាដែលអ្នកមីង?

ខ៖ លោកពុកខ្ញុំអ្ហោះ?

ក៖ ចាំ!

ខ៖ ឪពុកខ្ញុំឈ្មោះ ជុំ

ក៖ ឈ្មោះ ជុំ?

ខ៖ ចាំ! អ្ហោះឈ្មោះ ជុនៗ

ក៖ ឈ្មោះ ជុន តើចុះដូចជាម្ដាយរបស់អ្នកមីងគាត់មានស្វាមីតែមួយមែនទេអ្នកមីង?

ខ៖ មានពីរ!

ក៖ មានពីរហើយចុះស្វាមីគាត់ក្រោយឈ្មោះអីគេដែរ?

ខ៖ អ៊ំស្វាមីក្រោយនោះឈ្មោះ ម៉ក់ តែគាត់ខូចបាត់ហើយគាត់នៅកំពុងឆ្នាំងអ្នកគាត់ខូចនៅឯណោះឯងគាត់ខូចនៅកំពុងឆ្នាំងនុង។

ក៖ ចាំចុះម្តាយរបស់នាងមានអាយុប៉ុន្មានហើយ?

ខ៖ ម៉ែប៉ែតសិបឆ្នាំជាងហើយគាត់ចាស់ៗមែនទែន។

ក៖ ចាំគាត់រស់នៅសព្វថ្ងៃនៅទីណាដែរ?

ខ៖ នៅភ្នំក្រោមយើងនេះនិងឯងតែគាត់នៅនួកខាងណាំក។

ក៖ គាត់នៅជាមួយអ្នកណាដែរ?

ខ៖ នៅគាត់នៅជាមួយប្អូនពៅនៅជាមួយប្អូនពៅជាមួយគ្រួសារគាត់ក្រោយគាត់មានកូនបីនាក់ទៅនៅជាមួយអាប្រុសពៅនោះឯងមួយកូនពៅ

ក៖ អូចាំគាត់មានស្វាមីក្រោយហើយមានកូនក្រោយទៀតអ្ហោះ?

ខ៖ ចាំ

ក៖ អ៊ំអញ្ចឹងដូចជាតើម្តាយរបស់អ្នកមីងសុខទុក្ខគាត់អត់អីទេណោះមែនទេ ដូចថាសុខភាពរបស់គាត់អីអ្ហោះ?

ខ៖ ចាំអត់អីទេអូនអត់អីទេ

ក៖ គាត់ឈឺបន្តិចបន្តួចដូចតែចាស់ដទៃអញ្ចឹងណោះអ្នកមីង?

ខ៖ ចាំ

ក៖ តែកាលគាត់នៅពីក្មេងដែលថាកាលគាត់មានកំលាំងតើគាត់ប្រកបមុខរបរអីគេដែរអ្នកមីងដឹងទេ?

ខ៖ អ៎កាលណោះខ្ញុំទើបតែអាយុប្រាំពីរប្រាំបីឆ្នាំខ្ញុំឃើញគាត់លក់ដូចជា បបរគាត់ធ្វើសម្លរលក់អីអញ្ចឹងអ្នាសគាត់រកចិញ្ចឹមកូនពេលនិងកូនៗមិនទាន់បានប្រពន្ធនោះយើងមិនទាន់មានបានអីគាត់ចេះតែតស៊ូចញ្ចឹមកូនទៅខ្ញុំហេតុតែខ្ញុំនេះពៅគេមែនតែខ្ញុំដូចតែបងគេអញ្ចឹងម៉ែគាត់មានគ្រួសារក្រោយទៀតគាត់មានកូនបីយើងមិនត្រូវបងគេយើងមិនត្រូវជួយមើលជួយរកម្ដាយទៅណាំធ្វើនេះធ្វើនោះទៅគាត់ធ្វើនំអោយខ្ញុំដើរលក់ប្លូរអង្ករក៏មានព្រោះជំនាន់នោះយើងដែលចាយលុយឯណាំយើងចាយតែអង្ករនិងទៅក៏ធ្វើនំគរនំកងអីចេះតែដើរលក់ទៅណាស់អូនធ្វើមិចអោយតែបានស៊ីរស់ទៅណាស់គេៗមានប្រពន្ធទៅណាស់គេយកប្រពន្ធក្រោយទៅម្ដាយយើងមេម៉ាយបន្តទៅទៀតទៅមេម៉ាយតាំងពីអាយុឆ្នាំខាលយើងតលូវ?យើងនេះប៉ុន្មានសាមសិបឆ្នាំហើយណាស់អាខាលយើងមិនមែនអាខាលហែសិបជាងសែហាសិបនោះមិនដឹងអីមិនបានចាំដែរអាខាលនោះឯង។

ក៖ ចាំអញ្ចឹងចុះឪពុករបស់អ្នកមីងវិញតើគាត់ប្រកបមុខរបរអីគេដែលឪពុកដើមរបស់អ្នកមីងអ្នាស?

ខ៖ ឪពុកដើមអត់សូវដឹងផងតែលឺម្ដាយថាគាត់នៅទន្លេយើងនៅព្រែកទាល់យើងនេះកាប់តែអូសទេហើយរាយម៉ងបន្តិចបន្តួចអញ្ចោះឯងតែលឺតែគាត់និយាយទេណាស់!

ក៖ ចាំអញ្ចឹងរូបថតក៏អ្នកមីងអត់ដែលឃើញដែរ?

ខ៖ អត់ដែលបានឃើញសោះកាលនោះរប៉ាត់រប៉ាយអស់មិនមានសោះមិនដែលឃើញមុខលោកឪពុកណាំផងតែពេលធ្វើបុណ្យធ្វើទាននិងគេចឹងបានអុជធូបចង់ឃើញមុខលោកពុកបើមិនបានឃើញផ្ទាល់ក៏ឃើញតាមយល់សប្ដិបន្តិចទៅណាស់!

ខ៖ ចាំតែបានដូចបំណងដេសអ្នកមីង?

ខះ អត់ៗបានផងនិង

កះ អ្នកមីងចង់ឃើញអ្ហោះ?

ខះ ចង់ៗឃើញតែអត់បានតែនែកវាដូចថាគាត់ម៉ោដែរតែម៉ោរាងស្រពិចស្រពិលៗដើរធ្វើដូចមនុស្សដើរអន្លងៗនោះណាស់តែយើងអត់ស្គាល់មុខលោកពុកនោះក៏មើលទៅដូចតែមនុស្សដើរក្នុងយល់សប្តិក៏មិនដឹងថាមនុស្សមួយណាំនោះឯងបើយើងឃើញច្បាស់ចាស់អញ្ចេះដូចថាអូនឯងនៅជិតអីឃើញច្បាស់អញ្ចេះបានអីដឹងថាមករកអីអញ្ចឹងអ្ហាសហើយយើងដឹងមិនសូវច្បាស់អញ្ចេះយើងមិនអាចស្មានថាលោកពុកយើងមុខយ៉ាងមិចអីយ៉ាងមិចអ្ហាសយើងអត់ដឹង

កះ ចាំអញ្ចឹងឪពុកដើមគឺថាបាត់ដំណឹងតែម្តង?

ខះ ចាំ

កះ គាត់ស្លាប់ឬក៏គាត់មានប្រពន្ធក្រោយទៀត?

ខះ អត់ទេគាត់ស្លាប់!

កះ អំគាត់ស្លាប់គាត់ស្លាប់ដោយសារអីគេដែរអ្នកមីង?

ខះ លឺម៉ែខ្ញុំថាគេវ៉ៃគាត់ស្លាប់គាត់មកបន្សល់សប្តិប្រាប់ម៉ែខ្ញុំថានែកថាឯងមើលកូនអោយអាញផងអាញងាប់ហើយគេវ៉ៃអាញនិងត្បូងចបបីត្បូងចបទេហើយទម្លាក់រណ្តៅជុំគ្នាអ្ហោះនៅវត្តភ្នាព្រុំមិនដឹងវត្តភ្នាព្រុំនៅឯណាគាត់ស្លាប់នៅវត្តភ្នាព្រុំយើងនិងអូនឯងដែលដឹងទេនៅឯណាអូនឯងធ្លាប់ដើរអីអត់ដែលដើរទៅណាទេ

កះ ប្រាប់ច្បាស់អញ្ចឹងម៉ងអ្នកមីង?

ខ៖ ចាំ

ក៖ វត្តអីគេ?

ខ៖ វត្តភ្នាព្រុំ!

ក៖ ភ្នាព្រុំ ខ្ញុំអត់ដែលលឺទេតែប្រាប់ម៉ោគឺស្តែងៗចឹងម៉ង?

ខ៖ អ្ហឺចាប្រាប់ច្បាស់ដូចយើងមែនទែនអញ្ចេះឯង

ក៖ តែគាត់ស្លាប់ជំនាន់អាពតណោះមឹងគេវ៉ៃម៉ាបីត្បូងចប?

ខ៖ ចាំគេវ៉ៃជំនាន់អាពតគេវ៉ៃគាត់តែបីត្បូងចបទេ

ក៖ តលូវនិងក៏អ្នកមីងមិនដឹងរកសាកសព្វមកពីណាមិនបានទៅបញ្ចុះទៅធ្វើធាតុធ្វើកោដិអីក៏មិនបានព្រោះមិនដឹងគឺថា

ខ៖ ធ្វើហើយៗខ្ញុំធ្វើឧបកិច្ចនិងដូងហើយៗធ្វើរួចហើយធ្វើអោយរួចហើយទោះយ៉ាងណាក៏ត្រូវតែធ្វើដែរបើពុំបានគាត់យើងក៏ដែលបានប៉ិននិងអ្នាសអញ្ជើងគាត់កើតទៅជាស្អីក៏ត្រូវគិតគាត់ដែរលោកពុកធំណាស់ម្តាយធំណាស់។

ក៖ ចាំអូយអ្នកមីងជាមនុស្សម្នាក់ដែលដឹងគុណឪពុកម្តាយមែនទែនចុះឪពុកចុងអីគាត់អត់មានធ្វើបាបអ្នកមីងដូចថាវ៉ៃកូនប្តីដើមអីចឹងអ្នាសមានទេ?

ខ៖ អត់ទេអត់មានទេអត់មានដែលវ៉ៃខ្ញុំទេគាត់ស្រលាញ់!

ក៖ អត់ទេគាត់មនុស្សល្អដែរចុះមូលហេតុអីបានជាគាត់បែកគ្នាជាមួយម្តាយរបស់អ្នកមីង

ខ៖ គឺដោយសារកាលគាត់កើតអាពៅក្រោយនិងគាត់វះហើយគាត់អត់អាចមានកូនទៀតទេហើយក៏ព្រោះម្ដាយមីងក៏ចាស់ទៅហើយនិងឯប្ដីគាត់នោះគេនៅក្មេងជាងទៅគាត់ក៏បានប្រពន្ធក្មេងទៀតទៅណាស់គេយកទៅគេសុំយកក៏ម្ដាយមីងក៏អោយគាត់ថាយកក៏យកទៅខ្ញុំមិនបានថាអីទេខ្ញុំចាស់ទៅហើយយើងកូនស្រីតែយើងចាស់ដឹងហើយអូន! (សើច)

ក៖ ដល់គេយកអោយគេយកទៅមិនបានថាអីទេប៉ុនតែយើងចិត្តកូនស្រីយើងក្ដៅក្រហាយដូចតែគ្នានិងឯងចេះតែទ្រាំៗទៅៗងាប់ទាំងប្ដីទាំងប្រពន្ធទៅណាំជាមួយប្រពន្ធក្រោយគាត់ណាស់ងាប់ទាំងអស់គាត់ចំណាស់នេះហើយគាត់នៅរស់របស់គាត់គាត់ដើរអោយរង្គើស(រទើក)របស់គាត់ដើរឡើងឆឹល(សើច)អ្នកមិនដឹងគេថាគាត់អាយុប៉ុននិងថាត្រឹមអាយុហុកសិបអីនោះឯង។

ខ៖ អ៎ចាំតើម្ដាយឪពុករបស់អ្នកមីងដើមអីណាំដូចថាគាត់ធ្លាប់ទូន្មានប្រៀនប្រដៅកូនចៅថាយ៉ាងមិចខ្លះតាមដែលអ្នកមីងនៅចាំអ្នាស?

ខ៖ ចាំមានអីគាត់ប្រដៅតាសអោយយើងល្អត្រូវចេះមានគុណធម៌សីលធម៌កុំអោយយើងខិលខូចយើងពីដើមមិញយើងទំលាប់កូនយើងល្អណាស់មិនមែនអញ្ចឹងទេចាំសូម្បីតែខ្ញុំមានបញ្ហាកូនស្រីយើងអីណាស់យើងមានបញ្ហាអីគ្រាន់តែប្រុសក្រលងក៏ផើមដៃរគាត់ប្រដៅយើងអ្នាសមិនអោយយើងដើរពេញតែវាលទេខ្លាចប្រុសក្រលងដើងនោះយើងខ្លាចទៅណាស់មីងអត់ចេះអក្សរសាស្ត្រអីទេមីងបានរៀនថ្នាក់ទីបីអង្កាលនោះកាលនោះមិនធម្មតាទេណាស់ក្មួយគាត់អត់អោយទៅរៀនទេគាត់ថាមិនបាច់ទៅរៀនគេសខ្ញុំថាមិចបានមិនអោយខ្ញុំទៅរៀនអញ្ចឹងខ្ញុំចង់ៗចេះអក្សរគាត់ថាកូនឯងគ្រាន់តាចេះម៉ាមើលឈ្មោះទៅបានហើយបើរៀនច្រើនសរសេរសំបុត្រអោយប្រុសទេ(សើច)ខ្ជិលទៅរៀននៅមើលប្អូនទូចៗនោះហើយប្អូនយើងកាលនោះនៅទូចៗមាននរណាគេជួយគាត់បើគាត់មេម៉ាយទៅក៏មិនបានទៅរៀនទៅតាំងពីតាណោះឯងម៉ោតាំងពីអាយុប៉ុន្មានប្រាំបីឆ្នាំម៉ោចប់រៀនរបូត(ហូត)មិនបានមានសាលានិងគេទេរៀននៅក្រោមដើមត្រាចដើមអ៊ុយ(អី)និងឯងសៀវភៅមានតាយើងដាក់អាចង់ដៃយើងណោះណាស់ទៅហើយ! (សើច)

កៈ ពេលនិងអ្នកមីងរៀននៅសាលាឈ្មោះអីដែរ?

ខៈ អឺមានសាលាម៉ោពីណាបើរៀនក្រោមដើមឈើនិងមិនដឹងសាលាឈ្មោះអី(សើច)

កៈ អញ្ចឹងសាលានិងឈ្មោះសាលាក្រោមដើមឈើ(សើច)

ខៈ នោះឯង(សើច)គ្មានសាលាទេរៀនក្រោមដើមឈើនិង

កៈ អញ្ចឹងគ្រូអីគេម៉ោស្ម័គចិត្តម៉ោបង្រៀនអីអញ្ចឹងហើយយើងរៀនតាមភូមិចាំ

ខៈ គេស្ម័គចិត្តម៉ោបង្រៀនតាមភូមិយើងគ្រូយើងអីនិងអ្នកភ្លាសដូចថាយើងភូមិអីគេស្ម័គអីម៉ោបង្រៀនយើងកូនសិស្សអោយចេះទោណាស់តែបើគ្រូអង្គាលនោះខ្លឹមៗដែលនិងអ្នកភ្លាស

កៈ អ៎ចាំអញ្ចឹងសព្វថ្ងៃអ្នកមីងអាចអានអក្សរខ្មែរបានទេ?

ខៈ អត់ចប់បាត់ហើយខ្ញុំតែបើលេខបានលេខស្គាល់តែអក្សរខ្លះស្គាល់តាសអូនដូចថាអក្សរ ក ខ អក្សរ គដូចថាម៉ាអក្សរតួៗនៃក

កៈ ព្យញ្ជនៈ

ខៈ ចាំព្យញ្ជនៈអីបានដល់យកទៅបូកគ្នាចប់បាត់(សើច)

កៈ កុំអោយបូកគ្នាដាក់តាមួយៗទៅអ្នកមីងចេះអាន

ខៈ ចាំដាក់តែមួយៗចេះអានទាំងអស់តែបើលេខបូកចេញបូកប៉ុន្នានក៏ចេញដែរ

កៈ អ៎អ្នកមីងពូកែលេខ

ខៈ អោយតែអក្សរលូកគ្នាមនដឹងចេញអីតេសហើយអក្សរអីខ្លះអីចំណាំដូចថាពេលច្រៀងអីចំណាំ(សើច)

កៈ អូចាំមីងចេះច្រៀងទៀតចាំចុះដូចជាតើឪពុកម្ដាយរបស់អ្នកមីងធ្លាប់និយាយថាពីសាច់រឿងកាលគាត់នៅពូ ក្មេងមិចខអោយអ្នកមីងស្ដាប់ទេដូចថាកាលពីជំនាន់អាពតមិចខគាត់កំសត់មិចគាត់ប្រាប់អ្នកមីងថាមិចខ្លះ?

ខៈ អ៎កាលនៅអាពតគាត់កំសត់ណាស់គាត់កំសត់គ្មានអីរកអីមិនបានអោយកូនខហូបទេហើយម៉ាក់ខ្ញុំគាត់សរ សៃរខ្ចីខ្ញុំផងមានអីហូបទេថាវេទនាណាស់ទៅ! និយាយពីថាជំនាន់អាពតវាវេទនាទៅណាស់គាត់និយាយថា គាត់វេទនាណាស់កូនអើយកូនទំរាំចិញ្ចឹមកូនឯងបានប៉ិនណេះពេលគាត់និយាយម្ដងខខ្ញុំទឹកភ្នែកហើយយើង ចិញ្ចឹមកូនអញ្ចេះដែរវាវេទនាដែរស្រណោះគាត់យើងសម័យនេះយើងថាយើងវេទនាគាត់វេទនាជាងយើង ទៀតណាស់

កៈ ចាំអ្នកសម័យមុនអីណាស់

ខៈ អូយវេទនាណាស់អូនអើយគ្រាន់តអីទៅលេងនៃកកន្លែងយាយចេកយាយចមអ្ហាសទៅអង្គាលណោះគេតាំង រូបគាត់នៅជំនាន់អាពតអូយមើលទៅចង់ស្រក់ទឹកភ្នែកអោអាញ់អើយអាញ់ខថាជំនាន់នេះអាញ់ថាខ្លួនឯងពិបាក គេជំនាន់អាពតគេពិបាកជាងអាញ់ប៉ិនណាទៅមានអីអស្ចារ្យទេប៉ិននិងចេះតែរស់ខទៅ

កៈ ចាំអញ្ចឹងយាយតាខាងម្ដាយអីអ្នកមីងស្គាល់ទេថាគាត់មានឈ្មោះអីខ្លះអញ្ចឹងអ្ហាស?

ខៈ អត់ខអត់ស្គាល់ចប់ម៉ងលោកពុកនិងក៏មិនដែរនិយាយថាឈ្មោះដុននោះទៅបាត់សូន្យខ្ញុំអត់មានដឹងអីតេ សគ្នាទូចពេកនោះហើយទើបនិងកើតម៉ោង៉ាខបានប៉ុន្មានប្រហែលកន្លះខែបួនដប់ម្ដៃប៉ិនណោះឯងថាអស់ធំ ហើយថាកន្លះខែចុះ

កៈ ចាំចុះឪពុកយាយតាខាងឪពុកក៏អត់ដឹងដែររឹតតែអត់ដឹងទៀតហើយ?

ខៈ រឹតតែទៅទៀតហើយ(សើច)

កៈ ដូចថាកាន់តែឆ្ងាយទៀតហើយអ្នកមីងព្រោះឪពុកក៏អត់ស្គាល់ផង

ខៈ ចាំវារឹតតែឆ្ងាយកាន់តែវែងឆ្ងាយទៅទៀតហើយ

កៈ អញ្ចឹងអ្នកមីងប្រហែលជាអត់មានបងប្អូនដែលនៅក្រៅប្រទេសទេមើលទៅ?

ខៈ អត់មានទេអត់មានសោះ

កៈ ចាំគ្រួសារគេខ្លះពេលជំលៀសចុះជំលៀសឡើងទៅណាំកទៅដល់ប្រទេសថៃកាណាដាអីអញ្ចឹងអីណាស់

ខៈ ចាំបានទៅដែរៗទៅម៉ែខ្ញុំបានទៅតែបកមកវិញ(សើច)ចុះមកវិញអង្គាលណោះៗវែដាច់ទៅផ្ញើរខ្ញុំបងខ្ញុំដែលប្រាំប្រាំមួយនាក់និងនិងម្ដាយមីងខ្ញុំនិងកន្សែងសៃព្រៃយើងនិងអ្នាសទៅឡើងទៅហើយឡើងទៅម្នាក់ឯងមើលទៅបែកប្ដីហើយបែកកូនទៀតមិនទៅណាទេមិចៗទៅអោបកូនគាត់ទៅណាគាត់ចិត្តជាម្ដាយអ្នាសគាត់បកម៉ោយកខ្ញុំគេទៅអស់រលីងទៅនាំម៉ែកូនដើរបានដល់ជិតបីខែបានមកដល់យើងឯណេះវិញអូអនអើយមើលមិនឃើញទេវេទនាពីក្មេងដឹងអាមិចអីអាមិចតេស(សើច)ដឹងស្រាប់ហើយដូចពីក្មេងយើងមើលខ្លួនឯងមើលមិនឃើញថាជាអ្វីទេតាឡាប់តាលូតពេញព្រៃ(រត់ពេញព្រៃ)នោះឯងអោយតែរស់ទៅសម៉យនេះហើយអ្ហោះ

កៈ ចាំអញ្ចឹងមានន័យថាម៉ោសម៉យនេះអ្នកមីងគលូវធូរច្រើនហើយ?

ខៈ ចាំវារៀងធូរជាងមុនបន្តិចហើយ។

ខ៖ ចាំវាធូរហើយ។

ក៖ អញ្ចឹងដូចជាចូលមកសាច់រឿងអាពាហ៍ពិពាហ៍របស់អ្នកមីងវិញម្តងតើស្វាមីរបស់អ្នកមីងមានឈ្មោះអ្វីដែរ?

ខ៖ អឺឈ្មោះអូម្តាយលោកពុកគេឈ្មោះ ខាត់ ឈ្មោះ ខាត់ ឃាំង។

ក៖ អំម្តាយឪពុករបស់ស្វាមីរបស់អ្នកមីងម្អោះ?

ខ៖ ចាំឪពុកគាត់ឈ្មោះ ខាត់ ឃាំង។

ក៖ ឪពុកម្តាយក្មេកម្អោះ?

ខ៖ ចាំ! ឪក្មេកញ៉ុមហើយម្តាយក្មេកនោះឈ្មោះនែកអត់ស្គាល់លោកពុកគាត់ទេស្គាល់ឈ្មោះតែម្តាយឈ្មោះភាព។

ក៖ ចាំ! ចុះស្វាមីរបស់អ្នកមីងវិញមានឈ្មោះអ្វីដែរ?

ខ៖ ឈ្មោះ ជាតិ ឈ្មោះអឺៗគេមកនៅណេះគេមានឈ្មោះជាតិដល់កាលគេនៅស្រុកគេឈ្មោះ ឃាំង។

ក៖ ចាំឥលូវនិងឈ្មោះ ជាតិ គាត់យកត្រកូលអ្វីដែរ?

ខ៖ គាត់យកត្រកូលប៉ិននៅឯណោះគាត់យកត្រកូលខាត់ និងយកឈ្មោះ ឃាំងនិងឯងដល់អ្នកនៅស្រុកនោះស្គាល់តែគាត់ឈ្មោះជាតិទេគ្មាននរណាគេស្គាល់ឈ្មោះ ឃាំងនិងទេ។

ក៖ ចាំចុះសព្វថ្ងៃនេះដាក់ជាតិវិញណោះ?

ខ៖ ចាំអញ្ចោះឯង។

ក៖ ចុះគាត់ប្រកបមុខរបរអីគេដែរសព្វថ្ងៃ?

ខ៖ គាត់ទំពគ្រួសារទំពគាត់ទំពណាស់។

ក៖ គាត់ធ្វើការខាងទាហ៊ាន

ខ៖ ចាំខាងទាហ៊ានធ្វើទាហ៊ាន

ក៖ គាត់ចូលធ្វើជាទាហ៊ាននិងតាំងពីគាត់អាយុប៉ុន្មានដែរអ្នកមីងឬក៏មុនស្គាល់អ្នកមីងទៀត?

ខ៖ អូមុនស្គាល់ឆ្ងាយណាស់អូនធ្វើអូយគាត់ធ្វើជាទាហ៊ានឡើងប៉ុន្មានត្រលប់ហើយគាត់ថាធ្វើតាំងពីប៉ុន្មាននោះគាត់និយាយមិញនោះគាត់កាលនោះបែបប្រាំប្រាំមួយដន្តប់(ដប់ប្រាំដប់ប្រាំមួយឆ្នាំ)មកម្ល៉េះអ្ហោះកាលធ្វើទាហ៊ានតាំងពីជំនាន់មុនគេចាប់ទៅធ្វើទាហ៊ានទៅទៀតអ្ហោះគាត់ថាគាត់ដែលលើកកាំភ្លើងមានរួចឯណាគាត់អូសតែនិងដីរលំតែគេធាក់គាត់

ក៖ គាត់និយាយប្រវត្តិអោយអ្នកមីងស្តាប់អ្ហោះ?

ខ៖ នោះឯងររល់តែនិងគេធាក់គាត់ចូលតែនិងព្រៃចុះកាំភ្លើងវាអូសវាមិនរួចនោះវាធ្ងន់នោះអូសរនឹងរនោងចុះក្មេងទៅលើកកាំភ្លើងវាធ្ងន់អាណាស់ដល់អ៊ីចាស់អ៊ីកាន់នៅធ្ងន់ចង់ងាប់ទំរាំតែក្មេង

ក៖ គាត់ក្លាហានណាស់ណោះមីងណោះចុះតលូវគាត់នៅធ្វើដល់តលូវគាត់ធ្វើអស់ប៉ុន្មានឆ្នាំហើយតាមដែលអ្នកមីងដឹងអាចរាប់?

ខ៖ អូយយូរហើយកាលញ៉ុមជួបគាត់កាលនិងមួយពាន់ប្រាំបួនរយកៅបី(១៩៩៣)កាលជួបគ្នាអ្ហាសតលូវម៉ោដល់

ឥលូវវាប៉ុន្មាន? វាម្ភៃប្អូន(២៩)ឆ្នាំហើយណាស់អូនត្រូវហើយណោះម្ភៃប្អូនឆ្នាំហើយណោះមើលកូនញ៉ុមនោះកាលជួបគាត់ឆ្នាំចឥលូវកូនញ៉ុមមីអូនវាម្ភៃប្អូនឆ្នាំហើយញ៉ុមដឹងតែប៉ុននិងអ្ហែណាស់ដែលគាត់នៅរួមរស់ជាមួយញ៉ុមៗដឹងតែប៉ុននិងអ្ហែណាស់ញ៉ុមដឹងតែប៉ុននិងទេអាអង្កាលដែលគាត់មិនទាន់ម៉ោនៅជាមួយខ្ញុំៗអត់ដឹងទេ។

កៈ ចាំកាលដែលគាត់ធ្វើទាហ៊ាននិងគាត់ធ្វើនៅឯណាដែរអ្នកមីង?

ខៈ អីគាត់ធ្វើអង្កាលនោះគាត់ធ្វើតាមវត្តចេតដីអីនោះឯងនៅតែពេញសៀមរាបនេះឯងមានទៅណាទេប៉ុនគាត់បានឡើងវ៉ៃគ្រប់ច្រកអូនអើយមកនៅជាមួយអីៗនៅតែនិងព្រៃទេកំសត់ណាអង្គុយចាំមើលតែប្តីមកផ្ទះវិញនេះឯងចុះប្តីទៅវ៉ៃនៅសមរភូមិនោះអូយគ្រប់ច្រកតាណាក៏វ៉ៃដេសហើយយើងនៅផ្ទះតែម្នាក់យើងទៅមើលកូនទៅមានអ្នកស្រុកឯណាមកដើរអញ្ចេះទេណាកាលមុននោះនៅតែកណ្តាលព្រៃយប់ឡើងលឺតែសត្វយំតាមម៉ាជួរតាណេះហើយល្បីថាខ្មោចលងខ្លាំងអីណាស់អូយខ្មោចលងអាក្រក់ៗណាស់តែអីនៅអត់មានសោះអីដុតតែធូបនឹកតែគុណព្រះអង្គទៅណាអោយជួយតាមថែរក្សានិងហើយអូនអើយកំសត់ណាស់

កៈ ជីវិតប្រពន្ធទាហ៊ានអ្ហាស

ខៈ ប្រពន្ធទាហ៊ានកំសត់ណាស់កំសត់ណាស់អូនអត់ទេតែគេប្រពន្ធទាហ៊ានខ្លះគេមានគេអត់កំសត់ទេគេពិបាកពីស្រុកស្រែគេទៅក្រុងអ្ហាសតែអីអត់ទេមិនដឹងទៅក្រុងណាទេ(សើច)អីវាអត់ដែរមិនដឹងទៅណាទេនៅតែនេះឯងរងចាំតែប្តីនៅណេះឯង

កៈ តែឥលូវលោកពូដូចថាគាត់បានឡើងសក្តិយសអីនៅអ្នកមីង?

ខៈ ចាំ! មានតាស

កៈ អំចាំព្រោះគាត់ប្រឹងយូរហើយ

ខៈ ចាំគាត់ប្រឹងយូរហើយអូនវេទនាមិចក៏មិនដែលហ៊ានឈប់ទេ

កៈ ចាំព្រោះគាត់ស្រលាញ់ផ្នែកទាហ៊ាននិង

ខៈចាំគាត់ស្រលាញ់ណាស់អូនខ្ញុំធ្លាប់ចង់អោយគាត់ឈប់តាសកាលនោះ

កៈ មានកូនណាស្នងតំណែងគាត់ទេ?

ខៈ អត់! អត់មានទេអូនវេទនាណាស់មិនអោយធ្វើទេអូយវេទនាណាស់ក្លាយស្រីណាមកបានមួយកូនញ៉ុមគ្នាវេទនាដូចខ្ញុំ

កៈ អ្នកមីងនឹកឃើញមិនចង់អោយគេវេទនាដូចអ្នកមីង

ខៈ ចាំហើយយើងខិតខំអញ្ចឹងហើយមេន់កមេនោះសំដីក៏វាវេទនាណាស់អូនអើយ

កៈ សំដីអត់ពិរោះពិសារ

ខៈ អូអត់ពិរោះពិសារគេសហើយប្រាក់ខែដូចមិនមែនសម្តេចហ៊ុន សែនអោយណាដូចមេនិងលក់ដីស្រែអោយយើងអញ្ចឹងសម្តីអូស

កៈ ចាំតែលោកពូនៅតែទ្រាំធ្វើការបាន

ខៈ គាត់ទ្រាំៗណាស់អង្កាលទៅនៅព្រះវិហារកាលឆ្នាំពីរពាន់ប្រាំបី(2008)យើងនេះណាស់គាត់ទៅគេម៉ោឡើងអស់រលីងរាប់រយគេរត់ម៉ោវិញទាំងអស់គាត់នៅប្អូរនៅតែគាត់និងឯងនៅតែគាត់ទេសព្វថ្ងៃនេះម្លោះមានតែគាត់ទេដែលទៅពីសៀមរាបនេះម្លោះទៅព្រះវិហារអ្នកសមានតែគាត់ទេដែលនៅតស៊ូមិនចេញទៅណាទេគាត់ថាកុំអោយខូចមុខអង្គភាពដូចថាអង្គភាពបានចាត់តាំងគាត់ទៅអញ្ចឹងបើគាត់អត់ទៅក្លាយខូចមុខអង្គភាពដែលចា

ត់អោយទៅព្រោះបើយើងរត់ចេញម៉ោអង្គភាពមិនត្រូវខូចមុខទៅគាត់ចេះតែប្តូរតស៊ូនោះឯង។

កៈ អូចាំអញ្ចឹងសព្វថ្ងៃគាត់មានមុខរបរអញ្ចឹងដូចគ្នាចឹងគាត់ទទួលបានប្រាក់ខែដែលណោះអ្នកមីង?

ខៈ ចាំបាន

កៈ អញ្ចឹងគាត់ប្រហែលជាទទួលបានប្រាក់ខែប៉ុន្មានដែរទាហ៊ានសព្វថ្ងៃ?

ខៈ ប្តីខ្ញុំបានប្រាក់ខែមួយលានដុល្លាជាង

កៈ អូចាំមួយលានដុល្លាជាងដែរ

ខៈ ហើយសម្តេចតេជោលោកបានអោយដូចជាផ្ទះគំរូដីស្រែអីដែរដីស្រែចំនួនបីហត្ថហើយផ្ទះគំរូមួយប៉ុនណាណឹ(ធំសម្បើម)នៅព្រះវិហារនិងអ្នកស្រុកអោយដែរដើម្បីលើកទឹកចិត្តដែរ។

កៈ ចាំចុះហេតុអីបានជាអ្នកមីងអត់ទៅនៅផ្ទះនៅខេត្តព្រះវិហារ?

ខៈ បើប្តីអត់នៅក៏មីងអត់ហ៊ានទៅនៅទេខ្លាចមីងខ្លាចខ្យល់អូយខ្យល់ម៉ោម្តងៗអូនអើយដួលទាំងចេញមិនរួចមិនទាន់សុទ្ធតែងាប់ចុះដើមឈើមួយដើមធ្វើបង្គោលផ្ទះនិងធ្វើសរសរផ្ទះនោះវាអញ្ចឹងឯងណាស់បង្គោលផ្ទះប៉ុនៗណោះបើរលំម៉ោអីអូយអីអត់ហ៊ានទៅនៅទេ។

កៈ នៅនោះខ្យល់ខ្លាំងម្លោះ?

ខៈ អូខ្យល់ខ្លាំងណាស់ដួលទាំងអស់ហើយអួយខ្យល់ណាស់ហើយបើផ្ទះអីវិញខ្ពស់ទៀតណាំដប់ម៉ែតណាំចាំយ៉ាងខ្ពស់សាលឹម(សន្លឹម)ពេលអើតមើល។

ក៖ ចុះអ្នកមីងស្រលាញ់គ្នាដោយចិត្តនិងចិត្តឬក៏ឪពុកម្តាយជាអ្នករៀបចំផ្សំផ្គុំអោយ?

ខ៖ ពួកខ្ញុំស្រលាញ់ចិត្តនិងចិត្ត។

ក៖ អូអ្នកមីងស្រលាញ់គ្នាដោយចិត្តនិងចិត្តពេលអ្នកមីងបានជួបគាត់អ្នកមីងស្រលាញ់គាត់ដោយខ្លួនឯង?

ខ៖ អត់ទេកាលខ្ញុំជួបគាត់ខ្ញុំអត់ស្រលាញ់គាត់ទេនេះបើយើងនិយាយអោយអស់ទៅណាស់អូនគាត់ធ្លាប់មានប្រពន្ធហើយអីអត់ស្រលាញ់គាត់ទេអីអត់ចូលចិត្តអីអត់ចូលចិត្តទេដូចថាពេលអីដើរលេងអ្នាសជំនាន់និងយើងមានអីជិះតាពេលអីដើរលេងទៅក៏ឃើញកាត់ញ៉ែស្រីញ៉ែអីទៅអីអត់ចូលចិត្តគាត់ទេអីមិនយកខ្លួនបៀតទេប្រុសអញ្ចេះអ្ហោះដូចថាអញ្ចេះមិនបានស្អប់មិនបានអីគាត់ទេណាស់មិនបានទៅស្អប់ជេរបញ្ចោរគាត់អីតេណាគឺថាអត់ចូលចិត្តដើរចេញអត់និយាយដើរចេញអត់ចូលចិត្តៗទេនិយាយត្រង់តែម្តងអត់ចូលចិត្តសព្វថ្ងៃក៏ដោយគាត់ទៅសមរភូមិរាប់ឆ្នាំខែបានគាត់ម៉ោណាគេម៉ោសួរថាចេះថាចុះអីញ៉ុមថាកុំនិយាយសួរនាំរឿងងញ?ចឹងញ៉ុមអត់ចូលចិត្តទេកុំនិយាយពាក្យអញ្ចឹងដាក់ខ្ញុំៗអត់ចូលចិត្តទេ(សើច)អញ្ចេះខ្ញុំអត់ចូលចិត្តទេខ្ញុំថានែកនិយាយអោយស្រួលបួលណាប្រយ៉ត្នខ្ញុំអត់ចូលចិត្តទេណា

ក៖ ចាដោយសារអ្នកមីងអត់ចូលចិត្តអ្នកណាប្រើពាក្យសម្តីលេបខាយ(ឌឺដង)មើលងាយទេ។

ខ៖ ចាអត់ចូលចិត្តទេអត់ចេះនិយាយច្រើនដាក់តែមួយម៉ាត់អោយហែងឆ្អែតបើជ្រុលកុំមើលមុខគ្នាបណ្តោយមិនចូលចិត្តទេខ្ញុំតាំងពីក្មេងម៉ោមិនចូលចិត្តតែម្តង។

ក៖ ចុះកាលដែលអ្នកមីងជួបគាត់វិញជួបគាត់នៅឯណាដែរអ្នកមីង?

ខ៖ ជួបនៅយើងនៅឯភ្នំក្រោមយើងនេះឯង។

ក៖អុំចាតែពេលនិងគាត់កំពុងធ្វើអីគាត់កំពុងបម្រើការជាទាហ៊ាននៅនេះអ្ហោះ?

ខ៖ ចាំគាត់ធ្វើជាទាហ៊ាននៅនេះឯង

ក៖ ហើយអ្នកមីងរស់នៅនេះដែរ

ខ៖ចាំពេលនិងខ្ញុំរស់នៅនិងដែរ

ក៖ ចាំហើយអញ្ចឹងជួបគ្នា

ខ៖ ចាំ

ក៖ គាត់ដូចថាតាមស្រលាញ់អ្នកមីងយូរទេបានអ្នកមីងព្រម?

ខ៖ យូរសុទ្ធតែឡើងដល់ឆ្នាំអ្ហោះគាត់សុទ្ធតែយកកាំភ្លើងកាំអីផ្ទុងយើងអ្ហោះ

ក៖ អូយងាប់ហើយ

ខ៖ សួរចាស់ៗមើសហើយជំនាន់នោះជំនាន់គេចាប់ស្រីអ្ហាស

ក៖ មែនអ្ហោះអ្នកមីង?

ខ៖ គេសុទ្ធតែយកកាំភ្លើងរុកតាមជញ្ជាំងតាមអីអ្ហោះចុះមិនដឹងរត់ទៅណាចុះខ្ញុំខ្លាចគេផងមិនដឹងរត់ទៅណាគេមិនចាប់យើងគេចាប់ធ្វើបាបយើងទៅណាស់យើងមិនយកយ៉ាងមិច(សើច)បើនិយាយទៅនេះក្រោមអាពតបន្តិច(សើច)អាពតវាចាប់យើងរើសម្លាប់ធ្វើបាបនេះចាប់យើងយកធ្វើបាបចាប់ធ្វើប្រពន្ធអញ្ចឹងបានថាពិបាកណាស់អូនអើយ

ក៖ តែបានរៀបចំតាមប្រពៃណីដែលទេ?

ខ៖អត់បានរៀបចំតែសអត់បានទេ

ក៖ តែបានសែនព្រេងធម្មតា

ខ៖ បានតែទាល់តែញ៉ុមបានកូនញ៉ុមមីបងផ្ទះនេះឯងបានញ៉ុមសែន

ក៖ ចាំម៉្យាងដែរអញ្ចឹងតើអ្នកមីងគិតថាគាត់ជាមនុស្សប្រុសបែបណាដែរសព្វថ្ងៃសំរាប់អ្នកមីងគាត់ចេះយល់ទុក្ខធុរៈអ្នកមីងអត់គាត់កាចឬក៏ស្លូតអីអញ្ចឹងអ្នាស?

ខ៖ គាត់កាចៗណាស់អូនអើយ(សើច)

ក៖ គាត់កាច?

ខ៖ ចាំគាត់កាច

ក៖ កាចតែគាត់កាចមានបែបបទរបស់គាត់ណោះអ្នកមីងណោះ?

ខ៖ ចាំគាត់កាចមានបែបបត់ពីដើមមិញគាត់កាចណាស់ហើយអ្នកនៅភ្នំក្រោមនេះខ្លាចគាត់ណាស់ពីមុនគាត់ទាហ៊ានៗអង្គាលរដ្ឋកម្ពុជាកាលនោះគាត់កាចអាណាស់គាត់កាចណាស់អ្នកណាក៏ខ្លាចគាត់ដែរអ្នកឈប់មិនហ៊ានដើរមុខផ្ទះទេចុះមេថាតែឈប់មេដឹងតែអោយចាប់គាត់ចាប់ទៅតលូវនិងឯងញ៉ុមចេះតែលួចប្រាប់ឯងអើយឯងចែកគេរស់ទៅព្រោះអីអត់ចូលចិត្តទេគាត់ថាអូយអញ៉ំមិនដឹងនិយាយថាយ៉ាងមិចទេបើមេបញ្ជាម៉ោញ៉ុមថាលើកលែងខ្លះទៅកុំទៅខ្វល់មិនមែនទៅលុយយើងគេសលុយគេទាំងឡានៗបងឯងចេះតែដេញទៅដេញៗនិយាយគ្នាដល់ផ្ទះនិយាយគ្នាវិញម៉ោប្រាប់អោយប្តីធ្វើតែអំពើល្អអញ្ចេះឯងមិនដែលអោយប្តីធ្វើអំពើអាក្រក់ទេ

ក៖ ចាំចុះតើអ្នកមីងគិតថាតាំងពីមុនមកដល់សព្វថ្ងៃនេះតើអ្នកមីងគិតថាជីវិតរបស់អ្នកមីងមានការផ្លាស់ប្តូរហើយឬនៅដូចថាពីមុនអ្នកមីងទុក្ខលំបាកច្រើនតែតលូវអ្នកមីងធូរស្រាលជាងមុនធូរធារជាងមុនហើយងឹអញ្ចឹងអី

ណាស់?

ខ៖ និយាយទៅមីងពីក្មេងមីងពិបាកមែនមីងនៅក្នុងការដែលមីងពិបាកផ្លូវកាយតែមកដល់ឥលូវមីងពិបាកផ្លូវចិត្ត មីងសព្វថ្ងៃមីងពិបាកផ្លូវចិត្តណាស់បើតាមដែលមីងមានច្រកឯណាមីងទៅមីងទៅហើយមីងអត់នៅទេពិបាកណាស់

ក៖ ពិបាកនិងបញ្ហាអីដែរអ្នកមីងអាចប្រាប់បានទេ?

ខ៖ ហើយពិបាកនិងបញ្ហាប្ដីនិងឯង

ក៖ អ៎ចាំតែកូនអត់អីទេ

ខ៖ ចាំកូនអត់អីទេពួកគាត់ធម្មតា

ក៖ គាត់សុទ្ធតែជាកូនដែរដើរតាមគន្លងធម៌

ខ៖ ចាំៗៗ

ក៖ ចាំចុះហេតុអីបានជាអ្នកមីងអត់ទៅនៅផ្ទះនៅខេត្តព្រះវិហារ?

ខ៖ បើប្ដីអត់នៅក៏មីងអត់ហ៊ានទៅនៅទេខ្លាចមីងខ្លាចខ្យល់អូយខ្យល់ម៉ោម្ដងៗអូនអើយដួលទាំងចេញមិនរួចមិនទាន់សុទ្ធតែងាប់ចុះដើមឈើមួយដើមធ្វើបង្គោលផ្ទះនិងធ្វើសរសរផ្ទះនោះវាអញ្ចឹងឯងណាស់បង្គោលផ្ទះប៉ុនៗណេះបើរលំម៉ោអីអូយអីអត់ហ៊ានទៅនៅទេ

ក៖ នៅនោះខ្យល់ខ្លាំងអ្ហោះ?

ខ៖ អូខ្យល់ខ្លាំងណាស់ដួលទាំងអស់ហើយអួយខ្យល់ណាស់ហើយបើផ្ទះអីវិញខ្ពស់ទៀតណាំដប់ម៉ែតណាំចាំយ៉ាងខ្ពស់សាលឹម(សន្លឹម)ពេលអើតមើល

ក៖ ចុះអ្នកមីងស្រលាញ់គ្នាដោយចិត្តនិងចិត្តឬក៏ឪពុកម្ដាយជាអ្នករៀបចំផ្សំផ្គុំអោយ?

ខ៖ ពួកខ្ញុំស្រលាញ់ចិត្តនិងចិត្ត

ក៖ អូអ្នកមីងស្រលាញ់គ្នាដោយចិត្តនិងចិត្តពេលអ្នកមីងបានជួបគាត់អ្នកមីងស្រលាញ់គាត់ដោយខ្លួនឯង?

ខ៖ អត់ទេកាលខ្ញុំជួបគាត់ខ្ញុំអត់ស្រលាញ់គាត់ទេនេះបើយើងនិយាយអោយអស់ទៅណាស់អូនគាត់ធ្លាប់មានប្រពន្ធហើយអីអត់ស្រលាញ់គាត់ទេអីអត់ចូលចិត្តអីអត់ចូលចិត្តទេដូចថាពេលអីដើរលេងអ្នាសជំនាន់និងយើងមានអីជិះតាពេលអីដើរលេងទៅក៏ឃើញកាត់ញ៉ៃស្រីញ៉ៃអីទៅអីអត់ចូលចិត្តគាត់ទេអីមិនយកខ្លួនបៀតទេប្រុសអញ្ចេះអ្ហោះដូចថាអញ្ចេះមិនបានស្អប់មិនបានអីគាត់ទេណាស់មិនបានទៅស្អប់ដេរបញ្ចោរគាត់អីតេណាគឺថាអត់ចូលចិត្តដើរចេញអត់និយាយដើរចេញអត់ចូលចិត្តៗទេនិយាយត្រង់តែម្ដងអត់ចូលចិត្តសព្វថ្ងៃក៏ដោយគាត់ទៅសមរភូមិរាប់ឆ្នាំខែបានគាត់ម៉ោណាគេម៉ោសួរថាចេះថាចុះអីញ៉ុមថាកុំនិយាយសួរនាំរឿងងញ?ចឹងញ៉ុមអត់ចូលចិត្តទេកុំនិយាយពាក្យអញ្ចឹងដាក់ខ្ញុំៗអត់ចូលចិត្តទេ(សើច)អញ្ចេះខ្ញុំអត់ចូលចិត្តទេខ្ញុំថានែកនិយាយអោយស្រួលបួលណាំប្រយ័ត្នខ្ញុំអត់ចូលចិត្តទេណាំ

ក៖ ចាំដោយសារអ្នកមីងអត់ចូលចិត្តអ្នកណាប្រើពាក្យសម្ដីលេបខាយ(ឌីដង)មើលងាយទេ

ខ៖ ចាំអត់ចូលចិត្តទេអត់ចេះនិយាយច្រើនដាក់តែមួយម៉ាត់អោយហែងឆ្អែតបើជ្រុលកុំមើលមុខគ្នាបណ្ដោយមិនចូលចិត្តទេខ្ញុំតាំងពីក្មេងម៉ោមិនចូលចិត្តតែម្ដង

ក៖ ចុះកាលដែលអ្នកមីងជួបគាត់វិញជួបគាត់នៅឯណាដែរអ្នកមីង?

ខ៖ ជួបនៅយើងនៅឯភ្នំក្រោមយើងនេះឯង

ក៖ អ៎ចាំតែពេលនិងគាត់កំពុងធ្វើអីគាត់កំពុងបម្រើការជាទាហ៊ាននៅនេះអ្ហោះ?

ខ៖ ចាំគាត់ធ្វើជាទាហ៊ាននៅនេះឯង

ក៖ ហើយអ្នកមីងរស់នៅនេះដែរ

ខ៖ចាំពេលនិងខ្ញុំរស់នៅនិងដែរ

ក៖ ចាំហើយអញ្ចឹងជួបគ្នា

ខ៖ ចាំ

ក៖ គាត់ដូចថាតាមស្រលាញ់អ្នកមីងយូរទេបានអ្នកមីងព្រម?

ខ៖ យូរសុទ្ធតែឡើងដល់ឆ្នាំអ្ហោះគាត់សុទ្ធតែយកកាំភ្លើងកាំអីផ្ទុងយើងអ្ហោះ

ក៖ អូយងាប់ហើយ

ខ៖ សួរចាស់ៗមើសហើយជំនាន់នោះជំនាន់គេចាប់ស្រីអ្ហាស

ក៖ មែនអ្ហោះអ្នកមីង?

ខ៖ គេសុទ្ធតែយកកាំភ្លើងរុកតាមជញ្ជាំងតាមអីអ្ហោះចុះមិនដឹងរត់ទៅណាចុះខ្ញុំខ្លាចគេផងមិនដឹងរត់ទៅណាគេមិនចាប់យើងគេចាប់ធ្វើបាបយើងទៅណាស់យើងមិនយកយ៉ាងមិច(សើច)បើនិយាយទៅនេះក្រោមអាពត

បន្តិច(សើច)អាពតវាចាប់យើងវៃសម្លាប់ធ្វើបាបនេះចាប់យើងយកធ្វើបាបចាប់ធ្វើប្រពន្ធអញ្ចឹងបានថាពិបាកណាស់អូនអើយ

កៈ តែបានរៀបចំតាមប្រពៃណីដែលទេ?

ខៈអត់បានរៀបចំតេសអត់បានទេ

កៈ តែបានសែនព្រេងធម្មតា

ខៈ បានតែទាល់តែញ៉ុមបានកូនញ៉ុមមីបងផ្ទះនេះឯងបានញ៉ុមសែន

កៈ ចាំម៉្យាងដែរអញ្ចឹងតើអ្នកមីងគិតថាគាត់ជាមនុស្សប្រុសបែបណាដែរសព្វថ្ងៃសំរាប់អ្នកមីងគាត់ចេះយល់ទុក្ខធុរៈអ្នកមីងអត់គាត់កាចឬក៏ស្លូតអីអញ្ចឹងអ្នាស?

ខៈ គាត់កាចៗណាស់អូនអើយ(សើច)

កៈ គាត់កាច?

ខៈ ចាំគាត់កាច

កៈ កាចតែគាត់កាចមានបែបទរបស់គាត់ណោះអ្នកមីងណោះ?

ខៈ ចាំគាត់កាចមានបែបត់ពីដើមមិញគាត់កាចណាស់ហើយអ្នកនៅភ្នំក្រោមនេះខ្លាចគាត់ណាស់ពីមុនគាត់ទាហ៊ានៗអង្គាលរដ្ឋកម្ពុជាកាលនោះគាត់កាចអាណាស់គាត់កាចណាស់អ្នកណាក៏ខ្លាចគាត់ដែរអ្នកឈប់មិនហ៊ានដើរមុខផ្ទះទេចុះមេថាតែឈប់មេដឹងតែអោយចាប់គាត់ចាប់ទៅតលូវនិងឯងញ៉ុមចេះតែលួចប្រាប់ឯងអើយឯងចែកគេរស់ទៅព្រោះអីអត់ចូលចិត្តទេគាត់ថាអូយអញ់មិនដឹងនិយាយថាយ៉ាងមិចទេបើមេបញ្ចាម៉ោញ៉ុម

ថាលើកលែងខ្លះទៅកុំទៅខ្វល់មិនមែនទៅលុយយើងគេសលុយគេទាំងឡានៗបងឯងចេះតែដេញទៅដេញៗ និយាយគ្នាដល់ផ្ទះនិយាយគ្នាវិញម៉ោប្រាប់អោយប្ដីធ្វើតែអំពើល្អអញ្ចេះឯងមិនដែលអោយប្ដីធ្វើអំពើអាក្រក់ទេ

កៈ ចាំចុះតើអ្នកមីងគិតថាតាំងពីមុនមកដល់សព្វថ្ងៃនេះតើអ្នកមីងគិតថាជីវិតរបស់អ្នកមីងមានការផ្លាស់ប្ដូរហើយ ឬនៅដូចថាពីមុនអ្នកមីងទុក្ខលំបាកច្រើនតែតលូវអ្នកមីងធូរស្រាលជាងមុនធូរធារជាងមុនហើយងឹអញ្ចឹងអី ណាស់?

ខៈ និយាយទៅមីងពីក្មេងមីងពិបាកមែនមីងនៅក្នុងការដែលមីងពិបាកផ្លូវកាយតែមកដល់តលូវមីងពិបាកផ្លូវចិត្ត មីងសព្វថ្ងៃមីងពិបាកផ្លូវចិត្តណាស់បើតាមដែលមីងមានច្រកឯណាមីងទៅមីងទៅហើយមីងអត់នៅទេពិបាក ណាស់

កៈ ពិបាកនិងបញ្ហាអីដែរអ្នកមីងអាចប្រាប់បានទេ?

ខៈ ហឺយពិបាកនិងបញ្ហាប្ដីនិងឯង

កៈ អ៎ចាំតែកូនអត់អីទេ

ខៈ ចាំកូនអត់អីទេពួកគាត់ធម្មតា

កៈ គាត់សុទ្ធតែជាកូនដែរដើរតាមគន្លងធម៌

ខៈ ចាំៗៗ

កៈ ចាំចុះហេតុអីបានជាអ្នកមីងអត់ទៅនៅផ្ទះនៅខេត្តព្រះវិហារ?

ខៈ បើប្ដីអត់នៅក៏មីងអត់ហ៊ានទៅនៅទេខ្លាចមីងខ្លាចខ្យល់អូយខ្យល់ម៉ោម្ដងៗអូនអើយដួលទាំងចេញមិនរួចមិន

ទាន់សុទ្ធតែងាប់ចុះដើមឈើមួយដើមធ្វើបង្គោលផ្ទះនិងធ្វើសរសរផ្ទះនោះវាអញ្ចឹងឯងណាស់បង្គោលផ្ទះប៉ុនៗណេះបើរលំម៉ោអីអូយអីអត់ហ៊ានទៅនៅទេ

កៈ នៅនោះខ្យល់ខ្លាំងម្លោះ?

ខៈ អូខ្យល់ខ្លាំងណាស់ដួលទាំងអស់ហើយអួយខ្យល់ណាស់ហើយបើផ្ទះអីវិញខ្ពស់ទៀតណាំដប់ម៉ែតណាំថាំយ៉ាងខ្ពស់សាលឹម(សន្លឹម)ពេលអើតមើល

កៈ ចុះអ្នកមីងស្រលាញ់គ្នាដោយចិត្តនិងចិត្តឬក៏ឪពុកម្ដាយជាអ្នករៀបចំផ្សំផ្គុំអោយ?

ខៈ ពួកខ្ញុំស្រលាញ់ចិត្តនិងចិត្ត

កៈ អូអ្នកមីងស្រលាញ់គ្នាដោយចិត្តនិងចិត្តពេលអ្នកមីងបានជួបគាត់អ្នកមីងស្រលាញ់គាត់ដោយខ្លួនឯង?

ខៈ អត់ទេកាលខ្ញុំជួបគាត់ខ្ញុំអត់ស្រលាញ់គាត់ទេនេះបើយើងនិយាយអោយអស់ទៅណាស់អូនគាត់ធ្លាប់មានប្រពន្ធហើយអីអត់ស្រលាញ់គាត់ទេអីអត់ចូលចិត្តអីអត់ចូលចិត្តទេដូចថាពេលអីដើរលេងអ្នាសជំនាន់និងយើងមានអីជិះតាពេលអីដើរលេងទៅក៏ឃើញកាត់ញ៉ៅស្រីញ៉ៅអីទៅអីអត់ចូលចិត្តគាត់ទេអីមិនយកខ្លួនបៀតទេប្រុសអញ្ចេះម្លោះដូចថាអញ្ចេះមិនបានស្អប់មិនបានអីគាត់ទេណាស់មិនបានទៅស្អប់ដេរបញ្ចោរគាត់អីតេណាគឺថាអត់ចូលចិត្តដើរចេញអត់និយាយដើរចេញអត់ចូលចិត្តៗទេនិយាយត្រង់តែម្ដងអត់ចូលចិត្តសព្វថ្ងៃក៏ដោយគាត់ទៅសមរភូមិរាប់ឆ្នាំខែបានគាត់ម៉ោណាគេម៉ោសួរថាចេះថាចុះអីញ៉ុមថាកុំនិយាយសួរនាំរឿងងញ?ចឹងញ៉ុមអត់ចូលចិត្តទេកុំនិយាយពាក្យអញ្ចឹងដាក់ខ្ញុំៗអត់ចូលចិត្តទេ(សើច)អញ្ចេះខ្ញុំអត់ចូលចិត្តទេខ្ញុំថានែកនិយាយអោយស្រួលបួលណាំប្រយ័ត្នខ្ញុំអត់ចូលចិត្តទេណាំ

កៈ ចាំអញ្ចឹងតើអ្នកមីងមានកូនប៉ុន្មាននាក់ដែរ?

ខះ បីមីងមានកូនបីនាក់។

កះ ស្រីប៉ុន្មានប្រុសប៉ុន្មានដែរ?

ខះ ស្រីពីរប្រុសមួយនោះឯងអាប្រុសបេះដូនកាយអោយនុងឯងស្រលាញ់ម្តាយណាស់ប្រើទៅណាវីតខយប់ស្មាលណាក៏ទៅដេស

កះ គាត់ចិត្តបានគាត់ល្អគាត់ចេះគោរពប្រតិបត្តិឪពុកម្តាយ

ខះ នោះឯង

កះ អញ្ចឹងកូនរបស់អ្នកមីងគាត់ទៅធ្វើការអស់ហើយអីសព្វថ្ងៃនេះ?

ខះ កូនខ្ញុំមួយឡើងមកអង្គុយមិញដែលអង្គុយស្តាប់មិញ

កះ គាត់មានគ្រួសារហើយ?

ខះ ចាំគាត់មានគ្រួសារហើយ

កះ ចុះនេះកូនគាត់អ្នោះ?

ខះ ចាំនេះកូនគេ

កះ អាំដែលចៅមិញដែលអ្នកមីងប្រាប់ថាអ្នកមីងមានចៅមួយនិងអ្នោះ?

ខះ ចាំៗ

កះ ចុះម្នាក់ទៀត?

ខះ ម្នាក់ទៀតអត់ទាន់មានទេ

កះ ចឹងគាត់សព្វថ្ងៃប្រកបមុខរបរអីគេដែរ?

ខះ អំគាត់ធ្វើការនៅខេរិនហាងគេនោះណាស់នៅជិតអាកន្លែងពេទ្យបេះដូងឆ្មោះនៅម៉ុំនែក

កះ ចាំចុះគាត់ធ្វើការផ្នែកអីគេដែរ?

ខះ ផ្នែកអាពេទ្យដែលគេបីកូនងាឆ្មោះមុខអាពេទ្យបីកូនងានិងគេហៅផ្នែកដូចគេថាអាពេលគេកាត់សក់កាត់អីហើយយើងទៅថ្យាលសំអាតត្រចៀកហើយគេមានស្ទីមមុខស្ទីមអីផ្នែកបុរសឆ្អាសមានតែបុរសទេណាស់ដែលចូលឆ្អាសដូចថាមានបុរសជនជាតិគេអីគេចូលអាកន្លែងនិងកន្លែងថៃឆ្អាសអ្នកល្មមៗគេមិនហ៊ានចូលទេវាថ្លៃកាត់សក់សុទ្ធតែប្រាំដុល្លាប្រាំមួយដុល្លាអីន់តែបើខ្មែរយើងទៅកាត់សក់អីអស់តែពីរពាន់រៀលនិង(សើច)

កះ កន្លែងប្រេនឆ្អាសអ្នកមីង

ខះ ចាំនុងហើយ

កះ ចាំអញ្ចឹងដូចជាដូចថាពួកយើងបង្វែអារម្មណ៍វិញណាស់អ្នកមីងចង់សួរថាតើមុខម្ហូបអីដែលអ្នកមីងចូលចិត្តជាងគេ?

ខះ ខ្ញុំឆ្មោះអូយខ្ញុំស្អីក៏ចូលចិត្តដែលចូលចិត្តទាំងអស់នោះ

កះ អីយ៉ាអ្នកមីងចូលចិត្តទាំងអស់

ខ៖ ចុះបើវាសុទ្ធតែឆ្ងាញ់ទាំងអស់នោះ

ក៖ ព្រោះអ្នកមីងអត់ញ៉ាំរើស

ខ៖ អូញ៉ាំទាំងអស់អោយតែឆ្អិនញ៉ុមអត់រើសទេញ៉ាំទាំងអស់

ក៖ ចាំចុះតើមានម្ហូបដែលជាចំនូលចិត្តខ្លួនឯងមួយអ្នាសមានទេ?

ខ៖ អត់មានស្អីក៏ហូបដែរ

ក៖ ស្អីក៏ចូលចិត្តដែរអ្នោះ

ខ៖ អូយអោយតែឆ្អិនចូលចិត្តញ៉ាំទាំងអស់មិនចេះរើសនិងគេទេ

ក៖ ត្រីអាំងត្រីចៀនសម្លរឆាអីបានទាំងអស់?

ខ៖ អូចូលចិត្តទាំងអស់(សើច)

ក៖ ម៉ាអ៊ែមញ៉ាំទាំងអស់(សើច)ចុះតើអ្នកមីងអាចធ្វើម្ហូបបានច្រើនមុខទេ?

ខ៖ បានច្រើនមុខអត់តែម្ហូបយើងក្នុងហាងអត់ចេះតែម្ហូបខ្មែរយើងចេះទាំងអស់។

ក៖ ម្ហូបខ្មែរចេះទាំងអស់?

ខ៖ ចេះទាំងអស់!

កៈ ចេះតមកពីឪពុកម្តាយមកឬក៏អ្នកមីងរៀនដោយខ្លួនឯង?

ខៈ ចេះពីឪពុកម្តាយមកគាត់លក់គាត់ស្លរសម្លរលក់យើងមើលគាត់ជួយគាត់ៗមែនជួយស្លរតេសគាត់អោយយល់ដល់យើងថាអោយថែមអានេះថែមអានោះបង្រៀនយើងអោយចេះដល់តែថែមចុះថែមឡើងទៅឆ្ងាញ់ដល់ទៅអញ្ចឹងគាត់អោយយល់យើងអ្នកថាសម្លរម្ជូរអញ្ចឹងគេដាក់អីខ្លះហ៎កគាត់ថាដាក់ស្អីៗៗអញ្ចឹងអ្វាសដល់តែគាត់ប្រាប់ទៅយើងចេះដល់តែចឹងយើងចេះកូនញ៉ុមអីពេលចង់ស្លរអីគេតែម៉ោសួរអ្នកម៉ាក់អើយខគេដាក់មិចខ្លះម៉ាក់អើយខគេដាក់មិចខ្លះស្ងោរដាក់មិចខ្លះស៊ុបសាំងអីដាក់មិចខ្លះព្រោះយើងស៊ុបនោះយើងដាក់ផ្សេងយើងស្ងោរស៊ុបនោះយើងដាក់ផ្សេងប្រាប់កូនទាំងអស់ពួកខ្លះគេថាឃីអ្វាសស្អីក៏សួរម្តាយៗស្អីតិចក៏សួរឪពុ?ម្តាយដូចញ៉ុមថាអោយសួរម៉ោធ្វើមិចបើគ្នាអត់ចេះហើយបើកូនគ្នាសួរយើងៗក្រញ៉ាំងក្រញ៉ូវដាក់កូនវាខុសៗអីណាស់អូន

កៈ គ្នាអត់ចេះ!

ខៈ ចាំគ្នាមិនចេះគ្នាអត់ចេះយើងជាឪពុកម្តាយត្រូវអប់រំកូនប្រដៅអប់រំទូន្មានកូនអោយកូនធ្វើអញ្ចេះៗអោយដាក់នេះដាក់នោះ។

កៈ ចុះកូនច្បងអ្នកមីងមានឈ្មោះអីដែរ?

ខៈ ឈ្មោះនែក ជាតិ ស្រីលំក្ខ

កៈ ចុះកូនបន្តបន្ទាប់ទៀតឈ្មោះអីដែរ?

ខៈ បន្ទាប់មកទៀតទីពីរគឺជាតិ ស្រីលាភ បន្ទាប់មកទៀតជាតិ ស្រីឡៃអ្នោះប្រុសឡៃជាតិ ប្រុសឡៃ(សើច)

កៈ រកថាជាតិស្រីឡៃព្រោះស្រីលំក្ខ ស្រីលាភដល់មួយទៀតហៅស្រីឡៃ(សើច)

ខ៖ ចង់ហៅកូនស្រីឡៃទៀត(សើច)គាត់ឈ្មោះជាតិ ឡៃ

ក៖ ហើយចុះកូនពៅអ្នកមីងគាត់នៅរៀនក៏ឈប់ហើយ?

ខ៖ នៅតើគាត់រៀនថ្នាក់ទីដប់(10)

ក៖ អញ្ចឹងគាត់រៀនវេនព្រឹក?

ខ៖ ចាំវេនព្រឹក

ក៖ តែពីរឆ្នាំទៀតដល់ថ្នាក់ប្រលងបាក់ឌុបបាត់អញ្ចឹងអ្នកមីងមានបំណងចង់អោយគាត់រៀនអោយបានខ្ពស់ណោះអ្នកមីង?

ខ៖ ចាំអ្នកមីងចង់អោយកូនរៀនអោយខ្ពស់ប្រុសមួយនេះឯងបើកូនស្រីមុនៗរៀនមិនសូវបានខ្ពស់ទេរៀនបានត្រឹមថ្នាក់ទីដប់នៅសាលាឯយើងសាលាវត្តស្មៅយើងនេះឯងដល់អីរអត់មានលុយអោយរៀនតទៅក៏អោយឈប់កូនវាថាម៉ាក់អើយកូនឈប់រៀនទៅធ្វើការទៅព្រោះម៉ាក់អើយយើងក្របើបន្តរៀនមានលុយណាទៅរៀនអោយកូនធ្វើការទៅម៉ាក់ទៅក៏អោយកូនធ្វើហើយក៏កូនវាទៅធ្វើការម៉ាស្សាបានមួយថ្ងៃបីបួនម៉ឺននិងអូនហើយខ្ញុំមិនដឹងរកអីគ្រាន់តែយកលុយម៉ោបង់ទឹកបង់ភ្លើងអស់ៗខែខ្លះខ្វីគេព្រោះមិនគ្រាន់អូនអើយគ្រាន់តែបើកប្រាក់ខែម៉ោត្រូវទិញអង្ករផងឯណាបាយភ្លើងផងពេលបើកម៉ោយើងចាយអត់គ្រប់អ្ហាសធ្វើការទៅកូនអញ្ចេះឯណាំអូន។

ក៖ ចុះចម្រៀងវិញអ្នកមីងតើអ្នកមីងចូលចិត្តបទចម្រៀងដូចថាចូលចិត្តស្តាប់បទចម្រៀងអត់?

ខ៖ ចាំៗចូលចិត្តហើយអ្នកចម្រៀងដែលញ៉ុមចូលចិត្តស្តាប់មានតែបីនាក់ទេមាន ម៉េងកែវពេជ្រចិន្តា ,ហឹម ស៊ីវន និង ទូចស្រីនិច្ច បីនាក់ប៊ិនណោះឯងចូលចិត្តប៊ិនណោះឯងក្រៅពីនិងអត់ទេដូចអត់ចូលសោះអូនគេច្រៀងក្រ

ញ៉ុងក្រញ៉ាស់ដូចនិយាយនិង(សើច)ចេញម៉ោដូចនិយាយម៉ងនិងបើនិយាយដូចពិរោះជាង។

ក៖ ដូចជាបទខ្លះនិយាយញ៉ាប់ទៀត

ខ៖ ញ៉ាប់ទៀត

ក៖ ចាំអញ្ចឹងក្នុងបងប្អូនអ្នកមីងទាំងបងប្អូនជីដូនមួយបងប្អូនបង្កើតអ្នកមីងអត់មានអ្នកណាចេះខាងសិល្បះទេណោះអ្នកមីងណោះ?

ខ៖ អត់មានទេ។

ក៖ អូចាំ(សើច)ចុះផ្ទះរបស់អ្នកមីងកាលពីនៅក្មេងដូចផ្ទះរបស់អ្នកមីងឥលូវទេឬក៏តូចជាងឬក៏ធំជាង?

ខ៖ អំកាលពីនៅក្មេងអ្ហោះអី

ក៖ កាលពីអ្នកមីងនៅក្មេងអ្ហាស?

ខ៖ កាលពីមីងនៅក្មេងមីងនៅជំរុំគេធ្វើផ្ទះធំអ្ហាសគេអោយនៅផ្ទះនៅជំរុំគេធ្វើធំប៉ុន្តែគេធ្វើផ្ទាល់ដីអត់មានខ្ពស់អញ្ចេះទេនេះៗផ្ទះគ្រួសារទំពទេមីងគ្មានវាសនាបានធ្វើផ្ទះនៅទេព្រោះពេលបើកប្រាក់ខែម៉ោម្តងៗយើងជំពាក់គេយើងជឿគេហូបយើងធ្វើអោយគេបង់អោយគេអស់ៗបើយើងអត់ឈឺវាមិនអីទេណាស់តែយើងឈឺចប់ហើយអូន។

ក៖ អញ្ចឹងដូចជាតើអ្នកមីងមានជំនាញអីដែលតពីឪពុកម្តាយដែលទេដូចថាអ្នកមីងចេះធ្វើកន្ទេល ធ្វើអន្រឹង ធ្វើផ្តៅដែលឪពុកម្តាយបានបង្រៀននេះតៗម៉ោអញ្ចឹងអ្ហាស?

ខ៖ អ៎អីចេះធ្វើអន្រឹងកំបោក។

ក៖ អ៎ចាំ! ចេះពីម្តាយអ្ហោះ?

ខ៖ ចាំម្តាយបង្រៀនកាលនោះនៅក្រមុំអាយុដប់ប្រាំបីហើយគាត់ធ្វើអារបៀបឆ្និចឲអញ្ចេះដូចសំនុំឡយអញ្ចេះក៏សុំម៉ែសុំធ្វើមុនដំបូងវាងាករុះៗចាទំរាំតែកើតគាត់ក្អកផងអីផងថ្ងៃខ្លះក៏ខោកម៉ាកញ៉ររហើយគាត់រ៉ៃកុំខឹងគាត់ព្រោះគាត់រ៉ៃអោយយើងមានកំហឹងធ្វើអោយស្អាតទៅស្អាតរបស់យើងមែនមិនមែនរ៉ៃសម្លាប់កូនទេ។

ក៖ អញ្ចឹងបើអោយធ្វើសព្វថ្ងៃនេះអ្នកមីងនៅតែចាំអញ្ចឹងអ្ហាស?

ខ៖ ចាំចាំ អាចធ្វើបានតើ ចាំហើយញ៉ុមចេះចាក់កងដៃយើងអាពួកជនជាតិទិញពាក់ណ៎

ក៖ អូអ្នកមីងចេះធ្វើដែរ?

ខ៖ ចាំចេះតើៗ។

ក៖ ណ្ហកខ្សែកខ្ញុំៗមិនទាន់ចោលទេខ្ញុំចេះចាក់រូបចាក់អីដែលនិងអ្ហាស។

ក៖ អញ្ចឹងដូចជាក្រៅពីដែលអ្នកមីងនៅក្មេងនិងអ្ហាសដូចថាធ្លាប់ប្រកបមុខរបរអីគេដែរអ្ហាស?

ខ៖ អត់ដែលមានមុខរបរអីផ្ទាល់ខ្លួនៗឯងផងទាល់តែម៉ែបង្កើតដូចថាម្តាយគាត់បង្គាប់ប្រាប់អញ្ចឹងយើងធ្វើតាមគាត់ទៅណាស់

ក៖ អ៎ចាំអញ្ចឹងដូចថានៅជាមួយម្តាយរហូតម៉ោដល់តែពេលយើងមានគ្រួសារ

ខ៖ បានបែក!

កៈ បានប្ដីយើងគេបើកប្រាក់ខែម៉ោចិញ្ចឹមយើងវិញ?

ខៈ ចាំៗ

កៈ អញ្ចឹងអ្នកមីងអត់ដែលចេញទៅធ្វើនេះធ្វើនោះទេណោះ?

ខៈ អត់ទេអូនអត់ដែលទេ!

កៈ អំចាំ

ខៈ មិនដែលទេនៅតែផ្ទះមើលតែកូននិង

កៈ អំលោកពូអោយអ្នកមីងស្រណុកនិងអ្នាំគាត់ស្រលាញលប្រពន្ធខ្លាំង

ខៈ អត់ទេមិនដែលទៅណាទេអារបៀបមនុស្សប្រចំណ្ណប្រពន្ធមិនអោយដើរទៅណាំទេ(សើច)

កៈ (សើច)ចាំអញ្ចឹងដូចជាតើអ្នកមីងធ្លាប់មានក្ដីស្រមៃអីកាលនៅកាលពីក្មេងដែលចង់ចែកចាយឧទាហរណ៍មាន មនុស្សមួយចំនួនគាត់មានក្ដីស្រមៃគាត់ចង់ធ្វើគ្រូអីចឹងអ្នាសហើយចុះអ្នកមីងវិញធ្លាប់មានក្ដីស្រមៃអីអញ្ចឹងទេ?

ខៈ ពីមុនធ្លាប់ស្រមៃតាសតែមិនបានស្រមៃថាចង់ធ្វើគ្រូធ្វើអីទេចង់ដេរប៉ាក់ចាំដូចថាចង់ដេរប៉ាក់នៅផ្ទះនិងអ្នា សដូចថាមានម៉ាស៊ីនដេរមួយ ម៉ាស៊ីនផុង ម៉ាស៊ីនប៉ាក់ដោយអីនៅនោះធ្លាប់រៀនម៉ាស៊ីនផុងអ្នាសផុងផ្កាផុងអី អញ្ចឹងអីណាស់ចាំហើយអ៊ីចេះចាក់ស្រោមជើងស្បែកជើងមួកអីណាស់ចេះចាក់តើ

កៈ ចេះជំនាញច្រើនដែរណោះអ្នកមីងណោះ?

ខៈ ចេះចុះនៅឯណោះបងគាត់កាន់សមាគមន៏យើងហើយសមាគមន៏នុងវារបៀបអញ្ចេះរបស់ប្អូន វ៉ាមរិទ្ធអ្នកស្រីអី

កស្អីផ្ទូកតានេសអ្វោះទៅណាបាត់ហើយដូចអត់ដែលឃើញផងពេលអ៊ីនៅជំរុំអ៊ីរៀននៅសាលាដេរប៉ាក់និងអ្ហាសគាត់ម៉ោៗម្តងៗគាត់បើកជាក្រុណាត់ជាអីអោយយើងដេរជាអាវអីអក្មើងអ្ហាសហើយយើងអត់ចេះយើងអត់ចេះអក្មើងគេកាត់នៅក្រុណាត់សៀវភៅអក្មើងអ្ហាំអោយយើងកាត់ជារូបអាវដល់យើងចេះហើយអោយជាក្រុណាត់ម៉ោអ៊ីរៀនតើបងស្រីដែលនៅកាន់សមាគមន៍និងទៅគាត់យកទៅបង្រៀន។

កះ អូចាំតើអក្មើងដូចជាតើអ្នកមីងមានពាក្យពេជន៍អីផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយដែលទេដូចថាកូនចៅអីជំនាន់ក្រោយៗទៀតអក្មើងអ្ហាស?

ខះ មានចាំមាន(សើច)អោយជន! អូយមីងដូចមិនសូវចេះនិយាយ(សើច)

កះ (សើច)ដូចថាចំពោះការសិក្សា របស់ពួកគាត់អីអក្មើងអ្ហាស?

ខះ និងហើយអោយពួកគាត់អោយឆ្លាតអោយចេះព្រោះមីងវាមកដល់ដំណាក់កាលនេះវាចង់ល្ងង់វាចង់ភ្លេចទៅអស់ហើយអូនណាមួយ(អូម៉ោជាន់)ចាំព្រោះវាឧស្សាហ៍ឈឺឧស្សាហ៍អីផងយើងវាលើសឈាមលើសអីផងអ្ហាសហើយអ៊ីច្រើនតែកើតប៉ាស្ទិតដូចថាអ៊ីសន្លប់អត់ដឹងខ្លួនអ្ហាសដល់ពេលយើងម៉ោវិញដូចយើងភាំងដូចយើងអត់សូវចាំដូចមិនសូវដូចមុនដូចថាយើងវាចាស់ហើយស្មារតីវាភិតភាំងផងអ្ហាសទើបចង់អោយកូនចៅជំនាន់ក្រោយឆ្លាតៗកុំអោយល្ងិតល្ងង់ដូចមីងអក្មើងអ្ហាស

កះ ដូចថាអោយគាត់បានរៀន

ខះ ចាំអោយបានរៀនអោយខ្ពង់ខ្ពស់ខំតស៊ូ

កះ ចាំដោយសារជំនាន់ឥលូវគេមានអង្គការច្រើនហើយសាលាអីមានច្រើនហើយអីណាស់អ្នកមីងណោះអក្មើងគាត់អាចឆ្លៀតពេលដើម្បីរៀនច្រើនជាងអ្នកមីងបើអ្នកមីនគ្រាន់តែលែងតែមើលប្អូននិងក៏មិនបានរៀន

ខះ មើលប្អូនមើលក្មួយ

កះ ចាំពេលនិងមានសូវមានសាលាឯណាអ្នកមីង

ខះ មិនមែនមិនសូវមានអីអត់មានបណ្ដោយដូចថាអូនឯងចេះជាងគេអញ្ចឹងដូចថាយើងនៅជុំគ្នាអញ្ចឹងអីចង់អោយកូនចេះមានណាចេះទៅអោយគេបង្រៀនកូនខ្ញុំម៉ោដូចថាចែកប្រាក់ខែអោយចាយអញ្ចឹងអីណាស់ទៅក៏ដូចអូនឯងអញ្ចឹងអ្នកខ្លះគេថាខ្ញុំអត់យកទេបងអោយតែកូនក្មេងវាទៅរៀនក៏ទៅៗណាស់កាន់ការ៉ុងមួយទៅហើយមានអីសរសេរៗទេអានតែមាត់នោះរហូតដល់តែមួយពាន់ប្រាំបួនរយប៉ែត ប៉ែតមួយប៉ែតពីទើបគេសង់សាលាអោយនិងគេធ្វើសាលាអោយនិងពួកនិងគ្រប់អុនតាក់ទេដែលគេធ្វើសាលាអោយមានសៀវភៅរៀនមានសាលាមានតុអីអានិងកាលនិងឡើងមានតុហើយណាស់ហើយនៅឯជំរុំនិងគេឈប់មានសង្គ្រាមហើយមាននៅតែឯណោះឯងគេឈប់ហើយមីងក៏បានរៀនដល់ថ្នាក់ទីបីប៉ុនតែពេលរៀនៗចំតែសាលាលោក(សើច)ងាកលោកសុំសិល៍ងាកៗលោកសុំសិល៍គ្មានបានសូវរៀនតេស។

កះ អញ្ចឹងដូចជាអរគុណអ្នកមីងដែលបានចំណាយពេលវេលាអីណាស់អ្នកមីងណាំ

ខះ អញ្ចឹងចប់ហើយអូននេស?

កះ ចាំអញ្ចឹងដូចជាការសំភាសន៏នេះត្រូវបានបញ្ចប់អ្ហាសតែដូចជាសូមជូនពរអ្នកមីង

ខះ ចាំៗៗអូន

កះ ដូចជាជូនពរអ្នកមីងអោយប្រកបទៅដោយសុខភាពល្អហើយដូចជាចៅរបស់អ្នកមីងគាត់ប្រកបទៅដោយធម៌ហើយបញ្ញាឆ្លាតវៀងវៃដើម្បីតរៀនអោយបានការងារខ្ពស់ទៅអនាគតល្អចៅមួយសំនព្វនេះឯងហើយដូចជាបើកូនៗសូមអោយគាត់ធ្វើការងារសូមអោយការងាររបស់គាត់ប្រកបទៅដោយភាពជោគជ័យនិងរលូនហើយតាមផ្លូវមកផ្ទះធ្វើដំណើរត្រលប់មកផ្ទះទៅវិញទៅម៉ោពេលទៅធ្វើការសូមអោយសុវត្ថិភាពតាមផ្លូវទាំងទីចិត្តទី

ឆ្ងាយហើយសូមោយគាត់ដឹងគុណឪពុកម្ដាយចាំដូចជាអ្នកមីងលោកពូចឹងអោយអ្នកទាំងពីរមានសុខភាពល្អដើម្បីបន្តមានអាយុវែងនៅមើលភាពរកចំរើនតទៀតហើយក្ដីស្រមៃដែលអ្នកមីងមានទាំងប៉ុន្មានសូមអោយវាបានសំរេចដូចបំណងអ្នកមី?ផងដែរហើយដូចជាពួកយើងសុំការអនុញ្ញាតពីអ្នកមីងម្ដងទៀតដើម្បីដាក់សម្លេងនិងរូបថតរបស់អ្នកមីងចូលទៅក្នុងគេហទំព័ររបស់ពួកយើងអីណាស់អ្នកមីង?

ខ៖ ថតដាក់ចូលអីននោលគោកអក្មេងអ្ហោះ?

ក៖ អូអត់អីទេអ្នកមីងចាំស្លៀកពាក់ខោអាវរៀបចំខ្លួនហើយសិនចាំយើងថតក៏បាន។

ខ៖ អ៎អក្មេងអេស

ក៖ អក្មេងបានណោះអ្នកមីងណោះ?

ខ៖ ចា៎ៗៗ

ក៖ ដើម្បីអោយកូនចៅជំនាន់ក្រោយគេបានស្ដាប់លឺអ្ហាស!

ខ៖ ចា៎ៗៗ

ក៖ ចា៎អរគុណច្រើនអ្នកមីងសូមជំរាបលា!

ខ៖ ចា៎ជំរាបលា!